ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការគ្រប់គ្រង ដំណាំចំណីសត្វនៅតំបន់វាលទំនាប



រៀបចំដោយ **នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម**

សហការជាមួយ **នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល**

ឧបត្ថម្ភដោយ **គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី**

រៀបរៀងដោយៈ លោក លន់ សុផល
ទូរស័ព្ទៈ ០១២ ៩៥៨៨៣៥
អ៊ីម៉ែលៈ l.sophal@yahoo.com

កែសំរួលដោយៈ ជៀង សារិទ្ធ
ពិនិត្យ និងកែសំរួលដោយៈ លោកបណ្ឌិតរង ស៊ន សាន
នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល

កាលបរិច្ឆេទៈ ខែ កក្កដា ឆ្នាំ ២០០៦

© រក្សាសិទ្ធិគ្រប់យ៉ាងៈ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះជាកម្មសិទ្ធិរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID)តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្មការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគ ប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបានឆ្លង ការពិនិត្យពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់មន្ត្រី កសិកម្មស្រុកនិងភ្នាក់ងារ ប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុង បំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និងផលិតករដែលរស់នៅក្នុងតំបន់មានសក្តានុពលភាព ស្របតាមលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្ម កសិកម្មដើម្បី ធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យក ទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ “បទដ្ឋានអនុវត្តបច្ចេកវិទ្យា” ។ បអបពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យា ដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់អោយមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការ ក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀត ដែលបំរើការនៅក្នុង វិស័យអភិវឌ្ឍន៏កសិកម្ម នៅតាមមូលដ្ឋានប្រើប្រាស់។ បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈប្រភពជាច្រើន ដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗរបស់កសិករ។ បញ្ហាផ្នែកកសិកម្មរបស់កសិករត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ននានា ដូចខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួត ពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័តនិងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

# មាតិកា


**១. ការអធិប្បាយទូទៅ** ....... ១

**២. គោលបំណងចងក្រង** TIP : ....... ២

**៣. ការណែនាំលើការអនុវត្ត** TIP : ....... ៣

៣.១- ការជ្រើសរើសតំបន់គោលដៅសម្រាប់ដាំដុះដំណាំចំណីសត្វ ....... ៣

៣.២- វិនិច្ឆ័យទូទៅដោយមានការចូលរួម ....... ៣

៣.៣-វិនិច្ឆ័យជាក់លាក់ដោយមានការចូលរួម ....... ៤

៣.៤-សកម្មភាពពេលអនុវត្តន៍ដំណើរការដាំដំណាំចំណីសត្វ ....... ៤

**៤. ដំណាំចំណីសត្វដាំតាមប្លង់ដីភូមិ** ....... ៥

៤.១- គោលការណ៍គ្រឹះនៃការដាំដំណាំចំណីសត្វតាមប្លង់ដីភូមិ ....... ៥

៤.២- ដំណាំចំណីសត្វដាំសម្រាប់ការកាត់ផ្គល់អោយសត្វ ....... ៦

៤.៣- ការបែងចែកលំដាប់នៃប្រភេទពូជដំណាំចំណីសត្វ ....... ៧

៤.៤- លក្ខណៈទូទៅរបស់ប្រភេទពូជដំណាំចំណីសត្វសំខាន់ៗមួយចំនួន ....... ៨

**៥.ការដាំដំណាំចំណីសត្វ** ....... ១៩

៥.១-ការជ្រើសរើសទីតាំងដើម្បីដាំ ....... ១៩

៥.២-ការរៀបចំពូជដំណាំចំណីសត្វដើម្បីដាំ ....... ២៣

៥.៣-ប្រតិទិនដាំដុះដំណាំចំណីសត្វ ....... ២៥

៥.៤-បច្ចេកទេសក្នុងការដាំដំណាំចំណីសត្វ ....... ៣០

៥.៥- សំភារៈប្រើប្រាស់ក្នុងការដាំដុះដំណាំចំណីសត្វ ....... ៣៧

៥.៦- ការថែទាំដំណាំចំណីសត្វក្រោយពេលដាំ ....... ៣៨

**៦. ការគ្រប់គ្រងចំការដំណាំចំណីសត្វតាមគ្រួសារ** ....... ៣៨

៦.១- ការផ្ដល់ត្រឡប់មកវិញនូវជីជាតិដី នៅចំកាដំណាំចំណីសត្វ ....... ៣៩

៦.២- ការគ្រប់គ្រងសំអាតស្មៅចង្រៃ ....... ៤០

៦.៣- ការស្រោចស្រពដំណាំចំណីសត្វ ....... ៤០

៦.៤- កំពស់កាត់ និង ចន្លោះពេលនៃការកាត់ដំណាំចំណីសត្វ ....... ៤១

**៧. លទ្ធផលទទួលបានពីការដាំដំណាំចំណីសត្វ** ....... ៤២

**៨. ប្រភពគាំទ្រសកម្មភាព អនុវត្តដាំដុះដំណាំចំណីសត្វ** ....... ៤៣

**៩. ថវិកាសម្រាប់ការធ្វើបង្ហាញ**

## ១. ការអធិប្បាយទូទៅ

តំបន់វាលទំនាបនៃប្រទេសកម្ពុជា ជាទីតាំងមួយយ៉ាងសំខាន់ ប្រកបដោយដីមានជីជាតិដែលត្រូវបានចាក់បំពេញដោយដីល្បប់តាមរយៈទន្លេមេគង្គ និង បឹងទន្លេសាបនូវរដូវវស្សាជារៀងរាល់ឆ្នាំ។

តំបន់នេះមានដង់ស៊ីតេប្រជាជនរស់នៅច្រើនជាងតំបន់ខ្ពង់រាប ហើយភាគច្រើនជាកសិកររស់នៅពឹងផ្អែកសំខាន់ទៅលើភោគផលដែលបានមកពីផលិតកម្មកសិកម្ម។

ការងារចិញ្ចឹមសត្វៈ ជាផ្នែកមួយដែលសំខាន់ស្ថិតក្នុងចំណោមការងារចាំបាច់ របស់ប្រពន្ធ័កសិកម្មសមស្របនៅតំបន់វាលទំនាប។ ជាទូទៅ កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ដែលក្នុងមួយគ្រួសារៗ មានចិញ្ចឹម ជ្រូក មាន់ ទា និងជាពិសេស គោ ក្របី ដែលសំខាន់ប្រើជាកំលាំងអូសទាញ ភ្ជួររាស់ដី និង ដឹកជញ្ជូនកសិផលជារៀងរាល់ឆ្នាំ។ បើទោះជាពេលបច្ចុប្បន្នមានកសិករខ្លះមានលទ្ធភាពក្នុងការប្រើប្រាស់គ្រឿងយន្តកសិកម្មក្តី ក៏ពួកគាត់នៅតែត្រូវការ កំលាំងគោក្របី ដោយមិនអាចខ្វះបាន ។ លើសពីនេះទៀត សត្វក៏ជាប្រភពចំណូលគ្រួសារ និងការបំពេញអោយសេចក្តីត្រូវការម្ហូបអាហារជាចាំបាច់ផងដែរ។

បច្ចុប្បន្ន ការងារចិញ្ចឹមសត្វរបស់កសិករនៅតំបន់វាលទំនាប កំពុងជួបប្រទះនូវផលលំបាកយ៉ាងខ្លាំង ពីកង្វះខាតចំណីជាពិសេសចំណីសម្រាប់គោ-ក្របី ។ នៅរដូវវស្សា ដីទំនាបប្រហែល៧៥% ត្រូវលិចទឹកអស់ និងក្លាយជាវាលស្រែបំពេញទៅដោយដំណាំស្រូវ ដីទួលប្រហែល៥% ជាផ្ទៃដីភូមិ និងផ្ទៃដី ១៥-១៨% ជាចំការដំណាំរួមផ្សំ ឬ ដំណាំហូបផ្លែដូចនេះនៅសល់ផ្ទៃដីតិចតួចណាស់សម្រាប់ជាវាលចំណីសត្វធម្មជាតិ។

ដោយមានការខ្វះខាតបែបនេះនៅអំឡុងពេល ៤-៥ខែ ក្នុងរដូវវស្សា តំបន់ខ្លះ កសិករត្រូវចំណាយពេលដឹក គោ-ក្របីអោយដើរស៊ីស្មៅតាមភ្លឺស្រែ ឬ ចេញទៅរកស្មៅធម្មជាតិ នៅតំបន់ឆ្ងាយៗពីភូមិដោយប្រើរយៈពេលមិនតិចជាង ៤-៥ម៉ោង/ថ្ងៃ សម្រាប់បំពេញអោយសេចក្តីត្រូវការចំណីគោ-ក្របី ២-៣ក្បាលតែប៉ុណ្ណោះ។

ផលលំបាកនេះបានជះឥទ្ធិពលធ្ងន់ធ្ងរដល់ពេលវេលាបង្កបង្កើនផល ពេលវេលាចេញទៅរកកំរៃក្រៅពីកសិកម្ម និងជាពិសេសប៉ះពាល់ភាគច្រើនដល់ការងាររៀនសូត្ររបស់កុមារ ធ្វើអោយពួកគេបោះបង់ការរៀនសូត្រ ឬបង្ខំចិត្ត លក់គោ-ក្របី ឈប់ចិញ្ចឹម។

រដូវប្រាំង ភាពរាំងស្ងួតមានរយៈពេល៦ខែ ចំណីសត្វនៅតាមវាលធម្មជាតិត្រូវក្រៀមស្វិត ស្ទើរគ្រប់ទីកន្លែង គោ-ក្របី ទទួលបានភាគច្រើនគឺ ចំបើង ឬគល់ជញ្ជ្រាំង ដែលពុំមានជីវជាតិគ្រប់គ្រាន់ នាំអោយសត្វកង្វះអាហារូបត្ថម្ភ ស្គមបាក់កំលាំង ធ្វើអោយពន្យាពេលបន្តពូជ ងាយរងគ្រោះដោយជំងឺ អាចបង្កអោយស្លាប់ក៏មាន។

ដើម្បីជួយអោយស្ថានភាពនៃការចិញ្ចឹមសត្វនៅតំបន់វាលទំនាបមានលក្ខណៈល្អប្រសើរ និងកាត់បន្ថយបាននូវផលលំបាកមធ្យោបាយដែលល្អគឺ ការផ្សព្វផ្សាយនូវបច្ចេកទេសកែច្នៃចំណីសត្វ និងការដាំនូវប្រភេទដំណាំចំណីសត្វដែលផ្តល់នូវបរិមាណផល និងគុណភាពខ្ពស់ សម្រាប់ផ្តល់ជាចំណី បំប៉ន ឬជាចំណីបន្ថែមសម្រាប់សត្វ។

ក្រៅពីការចិញ្ចឹមសត្វ ស្រូវជាដំណាំស្បៀងសំខាន់ជាងគេ ដែលត្រូវបានផលិតឡើងជារៀងរាល់ឆ្នាំជាទូទៅកសិករនៅ តំបន់វាលទំនាបនាពេលបច្ចុប្បន្ន កំពុងអនុវត្តដាំនូវស្រូវបី ប្រភេទ គឺៈ

-ស្រូវធ្ងន់

-ស្រូវកណ្តាល

-ស្រូវស្រាល

ការដាំដំណាំស្រូវក៏បានរួមចំណែកក្នុងការដោះស្រាយផលលំបាកលើការងារខ្វះខាតចំណីសត្វព្រោះស្រូវក្រៅពីការបំពេញអោយតំរូវការស្បៀងសម្រាប់មនុស្ស អនុផល និងកាកសំណល់វា ត្រូវបានកសិករប្រើប្រាស់ជាចំណី សត្វ ដូចជាកន្ទក់ជាពិសេសចំបើងសម្រាប់ជាចំណីគោនៅរដូវខ្វះស្មៅ។

## ២. គោលបំណងចងក្រង TIP :

ការចងក្រងជា TIP មានគោលបំណងសំខាន់ៗមួយចំនួនដូចជា:

-ជាមធ្យោបាយក្នុងការចាប់ផ្តើមនៃការផ្សព្វផ្សាយបច្ចេកវិទ្យាដំណាំចំណីសត្វសមស្រមពីអ្នកបច្ចេក ទេសផ្សព្វផ្សាយទៅកសិករ និង អាចជួយអោយមានសកម្មភាពបន្តពី កសិករ ទៅកសិករ ដទៃទៀត។

-ផ្តល់នូវភាពសមស្របក្នុងការកែលំអប្រពន្ធ័ចំណីសត្វ ជាពិសេសចំណីគោក្របីចិញ្ចឹមជាលក្ខណៈគ្រួសាររបស់កសិកររស់នៅក្នុងតំបន់វាលទំនាប ដែលស្ថានភាពផ្ទៃដីវាលចំណីសត្វធម្មជាតិមានលក្ខណៈតូចចង្អៀតពិបាកក្នុងការពង្រីកផលិតកម្មសត្វ។

-ផ្តល់ជាឯកសារបច្ចេកទេស និងបទពិសោធន៍ខ្លះៗ សម្រាប់ជាការរួមចំណែកជាមួយអ្នកផ្សព្វផ្សាយអ្នកបច្ចេកទេសចំណីសត្វដើម្បីរួមគ្នាដោះស្រាយការលំបាករបស់កសិករ ដែលកំពុងជួបប្រទះយ៉ាងធ្ងន់ធ្ងរលើបញ្ហាកង្វះចំណីសម្រាប់សត្វ។

-ចូលរួមចំណែកក្នុងការជួយអោយកសិករមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការប្រើប្រាស់ធនធានធម្មជាតិ សមស្របរបស់គាត់អោយមានប្រសិទ្ធិភាព និងឈានទៅដល់ការពង្រីកផលិតកម្មសត្វ។

ដោយពិនិត្យឃើញនូវស្ថានភាពជាក់ស្តែងនៃការលំបាកក្នុងដំណើរការចិញ្ចឹមសត្វ ដែលបង្កឡើងដោយ កង្វះចំណីអាហារ ជាពិសេសសម្រាប់គោ ក្របី និងផលលំបាកដែលជះឥទ្ធិពលដល់ កសិករជាអ្នក ចិញ្ចឹមសត្វកំពុងជួប ប្រទះ។ ដោយឡែកកសិករនៅតាមតំបន់វាលទំនាប ដែលភាគច្រើនទទួលរងនូវការលំបាកនេះ ច្រើនជាងគេ ដូចជាចំណាយពេលច្រើនក្នុងការទៅរកចំណីសត្វ បាត់បង់ឱកាសក្នុងការចូលរួមក្នុងការងារសង្គម បាត់បង់ឱកាសក្នុង ការស្វែងរកចំណូលគួបផ្សំពីមុខរបរផ្សេង និងជាពិសេសកុមារមានការប៉ះពាល់ខ្លាំងដល់ពេលវេលាសិក្សាដូចជាទៅសាលាមិនទាន់ម៉ោងសំរេចចិត្តឈប់រៀនដើម្បីបំពេញតំរូវការចិញ្ចឹមគោ ក្របី។

តាមហេតុការណ៍ដែលកើតមានក្នុងសភាពជាក់ស្តែងនៅតំបន់ជនបទនៃប្រទេសកម្ពុជាយើង ជាពិសេសនៅតាមតំបន់វាលទំនាបនោះ TIP នឹងមានសរសេរនូវចំណុចជាច្រើនដែលអាចជួយអោយអ្នកអានមានលទ្ធភាពដកស្រង់យកទៅអនុវត្តន៍ ហើយទទួលបានជោគជ័យក្នុងការដាំដុះដំណាំចំណីសត្វទាញយកផលផ្តល់អោយសត្វ ឬបំប៉នសត្វអោយទទួលបានលទ្ធផលល្អ។

## ៣. ការណែនាំលើការអនុវត្ត បអប TIP :

ជាទូទៅការងារផ្សព្វផ្សាយអោយកសិករទទួលយកនូវបច្ចេកទេសដាំដុះដំណាំចំណីសត្វ វាពិតជាមានការលំបាក ទោះបីនៅតំបន់ដែលកំពុងជួបប្រទះនូវកង្វះខាតចំណីអាហារ សម្រាប់សត្វរបស់គាត់ក៏ដោយ។

ហេតុការណ៍នេះ កើតឡើងនៅគ្រប់តំបន់ដែលយើងមានការចាប់ផ្ដើមដំបូង ព្រោះវាមានការពាក់ពន្ធ័ទៅនិង ទំលាប់ក្នុងការចិញ្ចឹមសត្វ កំរិតនៃកាយល់ដឹង និងភាពជឿជាក់ទៅលើបច្ចេកវិទ្យារបស់កសិករដែលជាម្ចាស់សត្វ។

ដើម្បីជំនះបាននូវការលំបាកទាំងអស់ខាងលើ និងឈានទៅដល់ភាពជោគជ័យយើងគួរតែអនុវត្តជាជំហាន១ តាមគោលការណែនាំ ឬវិធីសាស្ត្រផ្សព្វផ្សាយដូចខាងក្រោមៈ

### ៣.១- ការជ្រើសរើសតំបន់គោលដៅសម្រាប់ដាំដុះដំណាំចំណីសត្វ

ដើម្បីធ្វើអោយការងារនេះទទួលបានជោគជ័យ និងដំណើរការទៅប្រកបដោយនិរន្តរភាព យើងចាំបាច់ត្រូវៈ

- សិក្សាជាដំបូងនូវទិន្នន័យមានស្រាប់ដែលមានការពាក់ពន្ធ័ និងការចិញ្ចឹមសត្វ នៅតាមមូលដ្ឋាន
- កំណត់បណ្ដោះអាសន្ននូវតំបន់ដែលគួរកំណត់យកធ្វើជាតំបន់គោលដៅដាំដំណាំចំណីសត្វ
- រៀបចំគំរូឯកសារស្រង់ព័ត៌មានដោយចុះទៅពិនិត្យ និងប្រមូលព័ត៌មានផ្ទាល់នៅកន្លែងដែលយើងបាន កំណត់ធ្វើយ៉ាងនេះដើម្បីច្បាស់ថាកន្លែងដែលកំណត់យកវាមានលក្ខណៈសមស្របក្នុងពេលអនុវត្តគំរោង។
- កំណត់បណ្ដោះអាសន្ននៅភូមិគោលដៅដែលពិនិត្យឃើញថាមានលក្ខណៈសម្បត្តិសមស្រប
- កំណត់ពេលវេលាដើម្បីធ្វើការប្រជុំភូមិដែលបានកំណត់បណ្ដោះអាសន្នដើម្បីបញ្ជាក់ពី គោលបំណង របស់ កម្មវិធី និងស្រង់ឈ្មោះកសិករដែលមានចំណាប់អារម្មណ៍ជាមួយកម្មវិធី កំណត់ពេលវេលា ដំណើរការ ជួបជាមួយកសិករដែលចាប់អារម្មណ៍ចូលរួម ក្នុងកម្មវិធីវិនិច្ឆ័យទូទៅដោយមានការចូលរួម។

### ៣.២- វិនិច្ឆ័យទូទៅដោយមានការចូលរួម

ការងារនេះគេចាប់ផ្ដើម អនុវត្តក្រោយពេលមានការប្រជុំភូមិ ២-៣ថ្ងៃ ដើម្បីទុកពេលអោយកសិករគិត ពិចារណា ពិភាក្សាមុនពេលសំរេចចិត្ត បន្ទាប់ពីការប្រជុំភូមិរួច។ ការវិនិច្ឆ័យទូទៅដោយមានការចូលរួមគេអនុវត្ត មានជំហាន មួយចំនួនដូចជាៈ

- សិក្សា ប្រមូលព័ត៌មានពាក់ពន្ធ័ នឹងប្រពន្ធ័កសិកម្មនៅតំបន់គោលដៅ
- សិក្សា និងវិភាគព័ត៌មានពាក់ពន្ធ័ និងការចិញ្ចឹមសត្វនៅតំបន់គោលដៅ
- កំណត់រកបញ្ហាសំខាន់ៗពាក់ពន្ធ័នឹងការចិញ្ចឹមសត្វ ហើយសាកល្បងដោះស្រាយដោយមតិអ្នកចូលរួម
- ចុងបញ្ចប់បង្ហាញគោលបំណងជាក់លាក់ និងកម្មវត្ថុដែលគំរោងនឹងត្រូវអនុវត្តជាមួយកសិករនៅពេល ខាងមុខ ហើយជាបន្តណាត់កសិករដែល មានការចាប់អារម្មណ៍ ដើម្បីចូលរួមក្នុងកម្មវិធីវិនិច្ឆ័យជាក់ លាក់ ដោយមានការចូលរួម។

### ៣.៣-វិនិច្ឆ័យជាក់លាក់ដោយមានការចូលរួម

ការងារនេះធ្វើឡើងក្រោយពេល១ថ្ងៃបន្ទាប់ពីដំណើរការវិនិច្ឆ័យទូទៅដោយមានការចូលរួម

ដំណើរការសកម្ម ភាពគឺៈ

-បង្ហាញអំពីលក្ខខណ្ឌសំខាន់ៗរបស់កម្មវិធី សម្រាប់ដំណើរគំរោង ដល់កសិករដើម្បីអោយគាត់ងាយក្នុងការ សំរេចចិត្តចូលរួម ឬ មិនចូលរួម។

-ស្រង់ឈ្មោះកសិករដែលសំរេចចិត្តចូលរួមហើយមានលក្ខខណ្ឌវិទ្ធិឆ្ល័យសមស្របដូចជាមានដីមានសត្វស្ម័គ្រចិត្តចូលរួមដោយមិនមានការបង្ខិតបង្ខំ ។

-ពិនិត្យស្ថានភាពជាក់ស្តែងនៅទីតាំងគ្រោងដាំដុះដំណាំចំណីសត្វរបស់កសិករដែលបានស្ម័គ្រចិត្តចូលរួម ។

-ណែនាំកសិករអោយដំណើរការការងារបណ្តើ១ ដូចជាត្រៀមសំភារៈជាពិសេសសំភារៈសម្រាប់ធ្វើរបងការពាររៀបចំដីសម្រាប់ដាំដំណាំចំណីសត្វជាដើម ។

-កំណត់ពេលវេលា ចាប់ផ្តើមដំណើរការដាំដុះដំណាំចំណីសត្វជាមួយកសិករអោយច្បាស់លាស់ ក្នុងករណីមានលក្ខខណ្ឌរំខានណាមួយនាំអោយមានការផ្លាស់ប្តូរពេលវេលា ត្រូវផ្តល់ដំណឹងអោយកសិករជាចាំបាច់ ។

### ៣.៤-សកម្មភាពពេលអនុវត្តន៍ដំណើរការដាំដំណាំចំណីសត្វ

សកម្មភាពនៅពេលអនុវត្តដំណើរការមានច្រើនដូចជាៈ

-បង្ហាត់កសិករអោយយល់ពីបច្ចេកទេសដាំដុះ និងគ្រប់គ្រងដំណាំចំណីសត្វ ដោយប្រើវិធីសិក្សាភ្ជាប់ និង ការអនុវត្តជាក់ស្តែង ។

-ដឹកនាំកសិករអោយមានដំណើរការទស្សនកិច្ចសិក្សា ពីតំបន់មួយទៅតំបន់មួយទៀត ដើម្បីអោយ គាត់មានឱកាសពិភាក្សាផ្លាស់ប្តូរគំនិត និងបទពិសោធន៍រវាងគ្នា និងគ្នា ។

-បង្កើតអោយមានកម្មវិធីទិវាស្រែកសិករនៅពេលរដូវប្រមូលផលលើកដំបូង ដោយមានកសិករដែលមិនទាន់បានអនុវត្ត និងកសិករកំពុងមានដំណើរការជាអ្នកចូលរួម ។

-ដឹកនាំកសិករចូលរួមទិវាស្រែ ចុះពិនិត្យស្រែ ដោយទុកឱកាសអោយកសិករដែលបានអនុវត្តហើយ ជាអ្នកបង្ហាញនូវបទពិសោធន៍ដែលខ្លួនបានធ្វើដល់កសិករថ្មីផ្សេងទៀត ហើយអ្នកសំរបសំរួលជាអ្នកជួយ បំពេញបន្ថែមចំណុចខ្វះខាត ។

-សាកសួរយោបល់នៅពេលចុងក្រោយទៅដល់ កសិករចូលរួមអំពីការសំរេចចិត្តរបស់ពួកគេទៅលើបច្ចេកវិទ្យានៅពេលខាងមុខ ។

-ស្រង់ឈ្មោះ ទីកន្លែងរបស់កសិករថ្មីប្រសិនបើគាត់មានសំណូមពរចង់ចូលរួមជាមួយកម្មវិធីដាំដុះដំណាំចំណីសត្វដើម្បីដំណើរការពង្រីកសកម្មភាពជាបន្តទៀតដោយមិនបាច់អនុវត្តការងារវិនិឆ្ល័យដោយមានការចូលរួមទៀតឡើយ ។

ការអនុវត្តបានតាមជំហានដូចបានរៀបរាប់ខាងលើនោះនិងជួយអោយការងារដាំដុះដំណាំចំណីសត្វប្រព្រឹត្តិទៅប្រកបដោយភាពជោគជ័យ និងមាននិរន្តរភាព រួមជាមួយការសាយភាយពីកសិករ ទៅកសិករ ផ្សេងទៀត ជាលំដាប់ រួមជាមួយការងារគ្រប់គ្រង និងត្រួតពិនិត្យបន្ថែម ។

## ៤. ដំណាំចំណីសត្វដាំតាមប្លង់ដីភូមិ

មានពូជដំណាំចំណីសត្វជាច្រើនប្រភេទដែលយើងអាចរៀបចំ ដាំវានៅតាមប្លង់ដី ភូមិជិត១ផ្ទះតាមលក្ខណៈ បច្ចេកទេសដោយវាមិនផ្តល់ផលប៉ះពាល់អ្វីទាំងអស់ដល់សុវត្ថិភាពរស់នៅរបស់យើង ។

ក្រៅពីផ្តល់ផលជាចំណីសត្វដំណាំចំណីសត្វប្រភេទខ្លះបានផ្តល់ប្រយោជន៍អោយយើងទៀតផង ដូចជាប្រភេទ លេហ្គឹម ដើមឈើមួយចំនួន គេដាំនៅតាមព្រំដីភូមិ ព្រោះវាអាចផ្តល់ជារបងរស់ដែលមានលក្ខណៈរឹងមាំ និងផ្តល់ ជាអុសសម្រាប់ប្រើជាថាមពលដុតចំអិនអាហារប្រចាំថ្ងៃបានដោយមិនចំណាយប្រាក់ និងពេលវេលាស្វែងរកវា។

ប្រភេទដំណាំចំណីសត្វខ្លះទៀតក្រៅពីផ្តល់នូវតំរូវការចំណីដែលមានគុណភាពដល់សត្វ វាអាចជួយកែប្រែ គុណភាពដីភូមិអោយមានលក្ខណៈល្អប្រសើរថែមទៀត ឬប្រភេទខ្លះទៀតវាជួយក្នុងការទប់ស្កាត់ ការហូរច្រោះ ដីទៀតផង ប្រសិនបើយើងដាំដុះ និងប្រើប្រាស់វាបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។

## ៤.១- គោលការណ៍គ្រឹះនៃការដាំដំណាំចំណីសត្វតាមប្លង់ដីភូមិ

ដីភូមិជាទីទួលដែលមានសុវត្ថិភាព ធានាដល់ការរស់នៅរបស់មនុស្ស និងសត្វដូចជាមិនលិចទឹកមិនមាន ការយាយីពីសត្វបំផ្លាញផ្សេងៗ និងជាពិសេសជាកន្លែងភាគច្រើនមានប្រភពទឹកអាចស្រោចស្រពដំណាំបានជាងនេះទៅទៀត ដីមានជីជាតិល្អហើយម្ចាស់មានលទ្ធភាពក្នុងការគ្រប់គ្រងបានជិតដល់ ។ លក្ខណៈទាំងអស់នេះវាអំណោយផលណាស់ សម្រាប់ការងារដាំដុះដំណាំចំណីសត្វ។

សម្រាប់ប្រទេសកម្ពុជាយើង ដំណាំចំណីសត្វដាំតាមគ្រួសារ នៅដីភូមិមានគោលការណ៍សំខាន់ ២ចំណុចៈ

គោលការណ៍ផ្សព្វផ្សាយ ***និង ផ្ទេរបច្ចេកវិទ្យា ដល់កសិករ***

-ផ្សព្វផ្សាយអំពីដំណាំចំណីសត្វនៅដំណាក់កាលដំបូង ដើម្បីអោយកសិករបានស្គាល់ពីប្រភេទ ដំណាំចំណីសត្វ និង យល់ដឹងពីសារៈសំខាន់របស់វា។

-ងាយក្នុងការបង្ហាញអោយកសិករដទៃមានទំនាក់ទំនង ទទួលយក និងមានការកែលំអរចំណីសត្វ

-អោយកសិករចេះរៀបចំដាំ និង ចេះប្រើប្រាស់ដំណាំចំណីសត្វបានសមស្របតាមលក្ខណៈជីវសាស្ត្រ

-កសិករមានលក្ខណៈងាយស្រួល និងមានពេលវេលាគ្រប់គ្រាន់ក្នុងការសង្កេតតាមដានលើការវិវឌ្ឍន៍ របស់ប្រភេទ ដំណាំចំណីសត្វនិមួយៗ។

-អោយកសិករមានចិត្តក្នុងការពង្រីកដំណាំចំណីសត្វដោយខ្លួនឯង តាមរយៈការយល់ដឹងរបស់គាត់ ។

គោលការណ៍សមស្របក្នុងការផ្តល់អោយសត្វ ***ស៊ី និង សំរួលការលំបាកដល់កសិករ***

-អោយកសិករមាន ចំណីសត្វនៅជិតផ្ទះសំរួល និងកាត់បន្ថយការខាតបង់ពេលវេលាច្រើនក្នុង ការស្វែងរកចំណីសម្រាប់សត្វ។

- កាត់បន្ថយដល់ការលំបាករបស់កុមារ ក្នុងការដឹកសត្វអោយស៊ី ទៅឃ្វាលសត្វ ឬស្វែងរកចំណីសត្វ

-សម្រាប់កាត់ និង ផ្តល់ជាចំណីបំប៉ន ចំណីបន្ថែម និង ចំណីសម្រាប់អោយសត្វស៊ីនៅរដូវប្រាំងរាស់ខ្លាំង។

## ៤.២- ដំណាំចំណីសត្វ ដាំសម្រាប់ការកាត់ ផ្តល់អោយសត្វ

គេអាចប្រើប្រាស់ប្រព័ន្ធដាំដុះដំណាំចំណីសត្វសម្រាប់ច្រូតកាត់ និងដឹកជញ្ជូនផ្តល់អោយសត្វដល់កន្លែងចិញ្ចឹមទោះ ក្នុងទំរង់ចិញ្ចឹមជាលក្ខណៈឧស្សាហកម្ម ឬលក្ខណៈគ្រួសារក្តី។ នៅកម្ពុជាយើងការរៀបចំបង្កើតអោយមានការដាំដុះដំណាំចំណីសត្វតាមប្រព័ន្ធកាត់ផ្តល់អោយសត្វស៊ីជាលក្ខណៈគ្រួសារ សម្រាប់តំបន់វាលទំនាបវាមាន លក្ខណៈសមស្របណាស់ ព្រោះតំបន់ទំនាបមិនសូវមានផ្ទៃដីទួលធំទូលាយដូចនៅតំបន់ខ្ពង់រាបឡើយ។

សកម្មភាពនេះបានអនុវត្តរួចមកហើយនៅស្រុកពញាក្រែក ស្រុកត្បូងឃ្មុំ ស្រុកកំពង់សៀម និង ស្រុកព្រៃឈរ នៃខេត្តកំពង់ចាម ដែលត្រូវបានកសិករចូលរួមដោយយកចិត្តទុកដាក់ និងផ្តល់នូវការគាំទ្រយ៉ាងខ្លាំង ។

សារៈប្រយោជន៍: ប្រព័ន្ធដំណាំចំណីសត្វតាមបែបកាត់ផ្តល់នេះមានលក្ខណៈពិសេស និងភាពចាំបាច់របស់ វាមួយចំនួនដូចជា:

-ជួយអោយកសិករជាម្ចាស់ចំការដំណាំចំណីសត្វមានការគ្រប់គ្រងល្អ និងចាប់អារម្មណ៍ខ្លាំងទៅលើ ចំការដំណាំចំណីសត្វរបស់គាត់ ។

-ជួយអោយកសិករមានចំណីសម្រាប់សត្វរបស់គាត់គ្រប់រដូវ ក្នុងនោះអាចប្រើប្រាស់ជាចំណីបន្ថែមចំណីបំប៉ន ឬសម្រាប់ផ្សំជាមួយអនុផលកសិកម្ម ជាចំណីបង្គ្រប់ អោយគោ-ក្របីនៅរដូវប្រាំង ។

-អាចអនុវត្តទៅបាននៅតំបន់វាលទំនាបដែលមានផ្ទៃដីទូលសម្រាប់ដាំដុះតូច ឬ ដាំបាននៅតាមដីប្លង់ផ្ទះ

-ជួយអោយដំណាំចំណីសត្វមានស្ថេរភាព និងដុះលូតលាស់ ល្អជាងការដាំ លែងអោយសត្វចូលស៊ីសេរី

-ដាំដំណាំចំណីសត្វក្នុង១សារ អាចប្រមូលផលបានច្រើនលើក និង ដុះលូតលាស់បានច្រើនឆ្នាំ ហើយសមស្របតាមលក្ខណៈបច្ចេកទេស ។

ចំណុចសំខាន់ៗក្នុងការគ្រប់គ្រងដំណាំចំណីសត្វ ***តាមលក្ខណៈកាត់ផ្តល់អោយសត្វ***

ដើម្បីអោយដំណើរការដាំដំណាំចំណីសត្វតាមរបៀបកាត់និងផ្តល់អោយសត្វទទួលបានជោគជ័យ អ្នកដាំគួរតែ យល់ដឹងនូវចំណុចសំខាន់មួយចំនួនដូចជា:

-តើយើងត្រូវកាត់ដំណាំចំណីសត្វប្រភេទនីមួយៗយ៉ាងដូចម្តេច ដើម្បីអោយវាលូតលាស់បានល្អ

-ចន្លោះពេលនៃការកាត់ ទៅតាមប្រភេទពូជដំណាំចំណីសត្វនីមួយៗ តើប៉ុន្មានថ្ងៃកាត់ម្តង ?

-កាត់ដំណាំចំណីសត្វរបៀបណាដែលសមស្រប ដើម្បីទទួលបាននូវផលច្រើន និងគុណភាពខ្ពស់

- អាយុកាលនៃការកាត់តាមប្រភេទរបស់ដំណាំចំណីសត្វ

-កំពស់នៃការកាត់តាមប្រភេទរបស់ដំណាំចំណីសត្វ

-កំរិតបាត់បង់នៃជីជាតិដី រួមជាមួយកំរិតជីជាតិ ដែលត្រូវបំពេញអោយដីវិញប្រចាំឆ្នាំ

-បច្ចេកទេសនៃការរៀបចំប្លង់ដាំដំណាំចំណីសត្វ ទៅតាមលំដាប់ប្រភេទនៃពូជនីមួយៗ ។

ក្រៅពីចំណុចទាំងអស់ខាងលើ ក៏នៅមានការងារមួយចំនួនដូចជា ការគ្រប់គ្រងថែរក្សា ការពង្រីកផ្ទៃដីដាំដុះបន្ថែម តំរូវតាមបរិមាណសត្វ ។ ដែលការងារទាំងអស់នេះវានឹងជួយរួមចំណែកធ្វើអោយទទួលបានជោគជ័យ ។

### ៤.៣- ការបែងចែកលំដាប់នៃប្រភេទពូជដំណាំចំណីសត្វ

ជាទូទៅដំណាំចំណីសត្វដែលមានស្រាប់នៅក្នុងស្រុក និង ដំណាំចំណីសត្វដែលបាននាំចូលពីបរទេសដាំនៅក្នុងប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ ត្រូវបានគេបែងចែកវាជាលំដាប់ថ្នាក់ដូចខាងក្រោម:




**ឈ្មោះប្រភេទពូជដំណាំចំណីសត្វសំខាន់ៗដែលបានដំណើរការដាំនៅកម្ពុជា**

| ពពួកស្មៅ **(Grass)** | ពពួកលេហ្គឹមដើមឈើ **(Treelegume)** | ពពួកលេហ្គឹម **( Legume)** |
|---|---|---|
| មុលឡាតូ ( Mulato) | កន្ធំថេត ( Leucaena) | ស្តាយឡូ ១៨៤ ( Stylo-184) |
| ម៉ារ៉ាន់ឌូ ( Marandu) | គ្លីរីស៊ីដ្យា ( Gliricidia) | ស្តាយឡូអាមាតា (Stylo Hamata) |
| ហ្គាមបា (Gamba) | ទ្រីចាន់ធារ៉ា ( Trychantra) | ដិសមិនធុស ( Desmenthus) |
| បាស៊ីលីស ( Basilisk) | មន ( Malbary) | ស្នោទូក (Aeschynomene amricana) |
| ប៉ាស្ពាលូម (Paspalum) | កាលៀនត្រា ( Callindra) | កាលូប៉ូ (Calopo) |
| ស្មៅហ្គីនេ (Ginea grass) | អង្គាដី ( Sesbania) | អារាក់ឈីពីនទាល់ ( Arachis pintoi) |
| ស្មៅដំរី ( Elephant grass) | | |
|ឃីងក្រាស ( King grass) | | |

បើយើងពិនិត្យជាទូទៅយើងឃើញថា មានប្រភេទដំណាំចំណីសត្វច្រើនជាង២០ប្រភេទ ដែលត្រូវបានគេនាំចូល ពីប្រទេសដទៃ ហើយមួយចំនួនមានដុះស្រាប់នៅក្នុងប្រទេសកម្ពុជាយើងជាលក្ខណៈធម្មជាតិ។

ពូជមួយចំនួនត្រូវបានបាត់ទៅវិញដោយការមិនទទួលយកពីសំណាក់ កសិករដោយគាត់បានគិតទៅដល់បរិមាណ គុណភាព និង លក្ខណៈសមស្របក្នុងការដុះលូតលាស់ ឬបន្សាំទៅនិងអាកាសធាតុក្នុងស្រុក។ បច្ចុប្បន្នឃើញមានតែ ជាង ១០ពូជប៉ុណ្ណោះ ដែលកសិករកំពុងដំណើរការដាំ ដោយឃើញថាវាមានប្រយោជន៍ សម្រាប់សត្វរបស់គាត់។

## ៤.៤- លក្ខណៈទូទៅរបស់ប្រភេទពូជដំណាំចំណីសត្វសំខាន់ៗមួយចំនួន

### ក-ក្រុមស្មៅ ( Grass )

មុលឡាតូ **( Mulato )**

មុលឡាតូ ឈ្មោះពេញគឺ Brachiaria hibrid CV Mulato ជាពូជបង្កាត់រវាង Ruziziensis x Brachiaria brizantha វាជាប្រភេទស្មៅកូនកាត់មិនអាចផលិតគ្រាប់បានទេសម្រាប់ការដាំនៅ ប្រទេសកម្ពុជាយើង ។

ស្មៅនេះដាំ សម្រាប់ផ្តល់ជាចំណីគោ-ក្របី ចៀម ពពែ វាស្ថិតនៅក្នុងក្រុមមានកំពស់ដើមមធ្យម លក្ខណៈពិសេសរបស់ Mulato គឺ:

-មុលឡាតូបាននាំគ្រាប់ចូលមកកម្ពុជាក្នុងឆ្នាំ ២០០៣ ដោយ CIAT-LLSP

-ជាប្រភេទស្មៅដែលមានលក្ខណៈធន់ទ្រាំបំផុត នៅរដូវក្តៅ និងសមស្របនឹងការកាត់ផ្តល់អោយសត្វ

-គុណភាពរបស់វាល្អជាងពពួកស្មៅដទៃទៀត

-ស្មៅប្រភេទនេះអាចផលិតគ្រាប់បាននៅ ក្នុងតំបន់ដែលមានរយៈកំពស់ខ្ពស់ ដូចជា ប្រទេសឡាវ

-បច្ចុប្បន្នការពង្រីកការដាំដុះបានដោយសារការបំបែកដើមដាំនៅរដូវវស្សាមានទឹកស្រោចគ្រប់គ្រាន់

-ការដាំវាត្រូវការប្រភេទដីដែលមានជីជាតិសមល្មម ហើយវាត្រូវការជីបន្ថែម ដើម្បីលូតលាស់ល្អ

-ដើមខ្លី មានស្លឹកច្រើនហើយទន់ និង មានរោមច្រើន សត្វចូលចិត្តស៊ី

-វាជាប្រភេទស្មៅដែលមានលទ្ធភាពបែកគុម្ពធំ និងសំបូរខ្នែងអាចបំបែកដាំបាន ។



ពូជស្មៅ មុលឡាតូ ( Mulato )

ម៉ារ៉ាន់ឌូ **( Marandu )**

ម៉ារ៉ាន់ឌូ ( Bracchiaria brizantha ) ជាប្រភេទស្មៅ សម្រាប់ផ្តល់ជាចំណីអោយគោ ក្របី ពពែរ៉ែយ មានប្រភពដើមនៅប្រទេសស៊ីមបាវេ (Zimbabwe) ហើយត្រូវបាននាំគ្រាប់ចូលមកប្រទេសកម្ពុជា នៅក្នុងឆ្នាំ ២០០៣ ដោយ CIAT-LLSP និងត្រូវបានដាំនៅស្រុកព្រៃឈរ ត្បូងឃ្មុំ កំពង់សៀម ពញាក្រែក។

ម៉ារ៉ាឌូជាប្រភេទស្មៅដែលមានកំពស់ដើមមធ្យម ហើយមានលក្ខណៈពិសេសមួយចំនួនដូចជា:

-ជាប្រភេទស្មៅដែលអាចដុះលូតលាស់ល្អ នៅលើដីដែលមានជីជាតិ ជាក់ស្តែងក្នុងការដាំនៅលើប្រភេទដីក្រហម (ក្រុមដីឡាបានសៀក) វាដុះលូតលាស់ល្អបំផុត ហើយដាំនៅលើដីឥដ្ឋខ្មៅ ក្រុមដីកំពង់សៀម កំរិតដុះល្អបង្គួរ និងអោយផលមធ្យមពេលដាំនៅលើក្រុមដីក្បាលពោធិ និងដីប្រទះឡាង។

-ម៉ារ៉ាន់ឌូមានការធន់ទ្រាំទៅនិងរដូវប្រាំងប្រហាក់ប្រហែល និងមុលឡាតូ ដែរ

- ម៉ារ៉ាន់ឌូមានដើម ស្លឹក វែងជាង មុលឡាតូ ហើយនៅជុំវិញគែមស្លឹក មានស្នាមជរៗ

-គេអាចដាំវាដោយគ្រាប់ និង ដោយបំបែកដើម ដាំនូវរដូវវស្សាហើយវាមានការដុះលូតលាស់ល្អ

- ស្មៅប្រភេទនេះវាមានលក្ខណៈសមស្របទៅនិងការដាំកាត់ផ្តល់ជាចំណីសត្វ

តាមលទ្ធផលស្រាវជ្រាវរបស់អ្នកឯកទេសផ្នែកដំណាំចំណីសត្វបង្ហាញថាស្លឹករបស់វានៅអាយុ២សប្តាហ៍ មានកំហាប់អាសូត (N) ២,៥% និង សារធាតុស្ងួតដែលរលាយបាន9 DM digestibility)៧៥% ហើយវា និងថយចុះជាងនេះនៅពេល វាមានអាយុលើសពីនេះ (R.M. Jones(Editors) ១៩៩២ )។



ហ្គាមបា **( Gamba )**

ជាប្រភេទស្មៅ ដែលស្ថិតក្នុងក្រុម អាត្រូប៉ូហ្គុន ហ្គាយានូស (Andropogon gayanus ) ពូជនេះគេបាននាំយកគ្រាប់មកដាំនៅខេត្តកំពង់ចាមក្នុងឆ្នាំ២០០៣ ដោយគំរោង LLSP-CIAT វាជាប្រភេទស្មៅសម្រាប់ផ្តល់អោយ គោ ក្របី ចៀម ពពែគ្រប់វ័យ ។ វាជាស្មៅដែលមានដើម និងស្លឹកតូចវែងមានរោមច្រើនហើយទន់ ជាទូទៅតាមការវាយ តម្លៃពីកសិករដែលបានដាំបញ្ជាក់ថា សត្វ គោ ក្របី ចូលចិត្តស្មៅនេះជាងគេ បើប្រៀបធៀប និងពេលដែលវា នៅខ្ចីដូចគ្នា។ លក្ខណៈពិសេសរបស់ ហ្គាមបា គឺៈ

-វាមានលទ្ធភាព ដុះលូតលាស់នៅលើដីគ្រប់ប្រភេទ រួមទាំងដី អាស៊ីត ដែលមិនសូវសំបូរជីជាតិ

-មានភាពធន់ទ្រាំនិងភាពរាំងស្ងួតរយៈពេលវែង ហើយនិងអាកាសធាតុក្តៅ

-ការដាំនៅក្នុងប្រទេសកម្ពុជាយើង វាមានសមត្ថភាពផលិតគ្រាប់ពូជបានល្អបង្គួរ ប៉ុន្តែគ្រាប់របស់ វាពេលទុំងាយ និងជ្រុះចេញពីទង មានការលំបាកក្នុងការប្រមូលទុក។

-គេអាចដាំវាដោយប្រើគ្រាប់ ឬ ដាំដោយរំលែកដើមនៅរដូវវស្សាក៏បាន ហើយវាសមស្របទៅ និងកាដាំសម្រាប់កាត់ផ្តល់អោយសត្វ។

-វាជាប្រភេទស្មៅដែលមានកំរិតដុះលូតលាស់ល្អបង្គួរ

-លក្ខណៈអន់របស់វាគឺ ឆាប់ឡើងដើម និងមានផ្កាច្រើន និងគុម្ពរបស់វាឆាប់ច្រោល ត្រូវការរំលែកដាំញឹកញាប់ជាងប្រភេទស្មៅដទៃទៀត។

ហ្គាមបា ជាមធ្យមក្នុងស្លឹករបស់វា មានកំរិតជាតិអាស៊ូត ២,៥% ហើយនិងកំរិតសារធាតុស្ងួតរលាយ ( DM digestibility ) ៦០%ពេលវានៅខ្ចី នៅក្នុងរដូវវស្សា ហើយកំរិតនេះនឹងថយចុះនៅពេលដើមវា ចាស់ជាពិសេស នៅរដូវប្រាំង (R.M. Jones(Editors) ១៩៩២ ) ។



ពូជស្មៅ ហ្គាមបា ( Gamba )

បាស៊ីលីស ( Basilisk )

ស្មៅបាស៊ីលីស ឬសិចញាល់ក្រាសជាប្រភេទស្មៅដែលមានដើមទាប វាសមស្របទៅ និងការដាំសម្រាប់លែងគោ-ក្របី អោយចូលស៊ី និង អាចដាំសម្រាប់ច្រូតកាត់ផ្តល់អោយសត្វស៊ីនៅតាមផ្ទះបានផងដែរ ។

ស្មៅបាស៊ីលីសបាននាំចូលមកដាំនៅកម្ពុជានៅក្នុងឆ្នាំ ២០០៣ នៅក្នុងខេត្តកំពង់ចាម ពិនិត្យជាទូទៅ វាជាប្រភេទស្មៅដែលមានលទ្ធភាពដុះលូតលាស់នៅលើដីស្ទើរតែគ្រប់ប្រភេទ រួមទាំងដីដែលមិនសំបូរជីជាតិផងដែរ លក្ខណៈពិសេសរបស់បាស៊ីលីសគឺៈ

-ជាប្រភេទស្មៅដែលមានអាយុកាលវែងបង្គួរ អាចធន់ទ្រាំនឹងរដូវប្រាំងនៅស្រុកយើងបាន

-វាមានការដុះលូតលាស់ល្អ ហើយក្រាស់ដើមតូចឆ្មារ ស្លឹកទន់ល្មម សត្វចូលចិត្តស៊ី

-គេអាចដាំវាបានដោយគ្រាប់ក្នុងកំរិត ៤-៦គក្រ/ហិតា ជំរៅកប់គ្រាប់ ២ ស.ម

-ការដាំដោយបំបែកដើម មានការ ដុះលូត លាស់លឿន និងងាយស្រួលថែរក្សាជាងដាំដោយគ្រាប់

-បាស៊ីលីសភាគច្រើនវាដួលនៅរដូវវស្សា ហើយការដួលនេះបណ្តាលអោយរលួយស្លឹកមួយចំនួនដែលជាហេតុនាំអោយសត្វមិនសូវស៊ី ដូចនេះនៅរដូវវស្សា យើងគួរខស្សាប៍កាត់វាជៀសវាងការដួល ។

តាមការសង្កេតជាទូទៅស្មៅប្រភេទនេះវាចាប់ផ្តើមផ្តល់ផលទាបនៅឆ្នាំទី៣-ឆ្នាំទី៤ ដូចនេះយើងគួរតែរៀបចំស្តូងវាឡើងវិញ ដោយប្រើគល់ចាស់របស់វា នៅរដូវវស្សាទើបជាការល្អ។

បាស៊ីលីសវាផលិតគ្រាប់មិនបានល្អទេ ចំពោះពូជដែលយើងកំពុងដំណើរការដាំនៅក្នុងប្រទេសយើង ។ ដូចនេះជាឱកាសក្នុងការពង្រីកបន្តគឺ ការបំបែកដើមដែលជាមធ្យោបាយប្រសើរបំផុត ។



ពូជស្មៅ បាស៊ីលីស ( Basilisk )

*ប៉ាស្គាលូម* **( Paspalum )**

ស្មៅប៉ាសស្គាលូម មានច្រើនប្រភេទដូចជា ប៉ាស្គាលូម ឌីឡាតាទូម (Paspalum dilatatum) ប៉ាស្គាលូម ណុតាទូម (Paspalumnotatum) ប៉ាស្គាលូមឌីស្ទិកជូម (Paspalumdistichum) និងប៉ាស្គាលូមអត្រាទូម ( Paspalum atratum ) ដែលបាននាំយកមកដាំនៅក្នុងខេត្តកំពង់ចាម ក្នុងឆ្នាំ២០០៤ ដោយគំរោង LLSP-CIAT ។

ពពួកស្មៅប្រភេទនេះគេអាចដាំវាបានដោយប្រើគ្រាប់ ៣-៥ Kg / ha ឬគេអាចប្រើដើមវា សម្រាប់រំលែកដាំ ក៏បាន ហើយមានលក្ខណះងាយស្រួលជាងការដាំគ្រាប់ ។ លក្ខណះពិសេសរបស់ស្មៅប្រភេទនេះគឺៈ

-ជាប្រភេទស្មៅដែលមានកំពស់ដើមមធ្យមដោយវាសមស្របនឹងការដាំនៅតំបន់ទមនាបកណ្ដាល នៃប្រទេសកម្ពុជាយើង ។

-ជាការល្អ គេដាំវានៅកន្លែងដែលទាប ហើយមានដក់ទឹកតិចតួចក្នុងរយះពេលខ្លី (១-២ថ្ងៃ)

-ស្មៅនេះវាត្រូវការកំរិតទឹកស្រោចស្រពខ្ពស់ជាងប្រភេទស្មៅផ្សេងៗទៀត ទើបដុះលូតលាស់ល្អ

-វាមានការដុះលូតលាស់លឿននៅរដូវវស្សាតែវាមិនសូវសមស្របទៅ និង រដូវប្រាំងដែលមានរយះពេល រាំងស្ងួតវែងដូចនៅកម្ពុជាយើង ដែលមានរដូវប្រាំងរហូតដល់ទៅ ៦ខែ ។

-ពពួកប៉ាស្គាលូម ភាគច្រើនអាចដុះលូតលាស់បាននៅលើ ដីខ្សាច់ដីជាតិ និងដីអាស៊ីតផងដែរ

-ស្មៅនេះសំបូរស្លឹក ហើយស្លឹកវាទន់ល្អនៅអាយុ៤៥-៦០ថ្ងៃ ស្លឹកប្រែជារឹងលឿនទៅតាមអាយុ ជាទូ ទៅពួកប៉ាស្គាលូម មានកំរិតអាសូតនៅក្នុងស្លឹក០,៨-២% កំរិតនៃសាធាតុរលាយ ៣៥%-៦០% ហើយមានការ ប្រែ ប្រួលទៅតាមអាយុរបស់វា និងទៅ តាមប្រភេទដីនៅកន្លែងដាំ ( R.M.Jones (Editors)1992 )

ប៉ាស្គាលូម ជាប្រភេទចំណីសម្រាប់ គោ ក្របី ចៀម ពពែ ហើយផ្ដល់នូវការលូតលាស់បង្គួរ ។



ពូជស្មៅ ប៉ាស្ពាលូម ( Paspalum )

ស្មៅហ្គីនេ **(Guinea grass)**

ស្មៅហ្គីនេ ឈ្មោះពេញរបស់វាគឺ ប៉ានីគូមម៉ាក់ស៊ីមូម ( Panicum maximum ) ជាប្រភេទស្មៅចំណីសម្រាប់គោ ក្របី ចៀម ពពែ សេះដែលមានគុណភាពល្អ ។ ស្មៅនេះត្រូវបាននាំចូលដំបូងគេមកក្នុងប្រទេសកម្ពុជា អំឡុង ឆ្នាំ ១៩៨៦ ដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ដាំសម្រាប់ផ្តល់អោយគោពូជនៅស្ថានីយ៍ ចិញ្ចឹមគោភ្នំតាម៉ៅ តែមិនទាន់មានការផ្សព្វផ្សាយដល់កសិករនៅឡើយ ។ ជាបន្ទាប់គំរោង CAAEPក្នុង អំឡុងឆ្នាំ ១៩៩៨ និងបានធ្វើការ ផ្សព្វផ្សាយពូជជាលើកដំបូងដល់កសិករ ។ បច្ចុប្បន្នពូជនេះ ត្រូវបាននាំចូលមកបន្តទៀតដោយ CIAT -LLSP និងត្រូវបានដាំផ្សព្វផ្សាយតាមគ្រួសារកសិករក្នុងខេត្តកំពង់ចាម ។

ប៉ានីគូមម៉ាក់ស៊ីមូមជាស្មៅដែលមានដើមខ្ពស់សមស្របណាស់សម្រាប់ការកាត់ និង ដឹកជញ្ជូនផ្តល់អោយសត្វស៊ីនៅកន្លែងចិញ្ចឹមលក្ខណៈពិសេសរបស់ស្មៅប្រភេទនេះគឺៈ

-វាមានទំរង់ដើមប្រហាក់ប្រហែលនិងស្រូវ តែគល់របស់វាមានពណ៌ស្វាយ

-ជាប្រភេទស្មៅដែលសំបូរស្លឹក និងមានការដុះលូតលាស់បែកគុម្ពធំក្នុងលក្ខខណ្ឌសមស្រប

-វាអាចដាំបាននៅលើដីដែលមានជីជាតិ ខ្ពស់ និងមធ្យម ហើយវាលូតលាស់បានល្អ

-ស្មៅប្រភេទនេះគេអាចដាំវាបានដោយគ្រាប់ និង ពិសេសការបំបែកដើមដាំ វាលូតលាស់លឿន

-ចំពោះការដាំនៅតំបន់វាលទំនាបនៃប្រទេសកម្ពុជាយើងស្មៅនេះផ្តល់ផលគ្រាប់ល្អ ប៉ុន្តែពិបាកក្នុង ការប្រមូលព្រោះគ្រាប់របស់វាតូច និងងាយក្នុងការជ្រុះចេញពីទងរបស់វា ។

-ប៉ានីគូមម៉ាក់ស៊ីមូម មានការដុះលូតលាស់លឿនជាងប្រភេទស្មៅដទៃទៀតនៅរដូវវស្សា តែកំរិតនៃ ការធន់ និង ភាពរាំងស្ងួតមធ្យម ជាទូទៅវាឆាប់ស្រពោនស្លឹកនៅរដូវប្រាំងក្តៅខ្លាំង ។

ប៉ានីគូមម៉ាក់ស៊ីមូម ពេលស្លឹកវានៅខ្ចីវាមានកំរិតអាសូត ( N ) ជុំវិញ ២% ហើយកំរិតនៃសារធាតុរលាយ (Digestibilities) ចាប់ពី ៥៨%-៦៤% ( Mannetje and R.M. Jones(Editors)1992) ។



ពូជស្មៅ ហ្គីនី (Guinea grass)

ស្មៅដំរី **( Elephan grass)**

*ស្មៅដំរីជាស្មៅមួយប្រភេទដែលស្ថិតនៅក្នុងក្រុម នេពារ* ( Napier grass ) *ហើយក៏ជាចំណីសម្រាប់ពពួកសត្វទំពារអៀង សំខាន់បំផុតគឺគោ ក្របី និងពេលខ្លះដើមដែលខ្ចីៗគេអាចយកវាផ្តល់ជាចំណីបន្ថែមសម្រាប់ជ្រូក និងមាន់ផងដែរ ។ស្មៅដំរីជាប្រភេទស្មៅដែលមានដើមខ្ពស់សមស្របទៅ និងការកាត់និងផ្តល់ដល់សត្វនិងជាពិសេស ស្មៅនេះផ្តល់នូវគុណភាព និង បរិមានផលខ្ពស់ លក្ខណៈខ្លះៗរបស់វាមានៈ*

*-ជាស្មៅចំណីសត្វមានគុណភាព ដែលជាទូទៅវាមានសារធាតុអាស៊ូត* ( N) *ក្នុងស្លឹកខ្ចី ២-៥%ហើយ កំរិតនៃសមាសធាតុដែលអាចរលាយបានពី* (DM digestibility) *៧០-៧៥% ដែលអាចចាត់ទុកថាជាកំរិតចំណីដែល មានអាហារូបត្ថម្ភខ្ពស់សម្រាប់ការលូតលាស់របស់សត្វ តែកំរិតនៃសារធាតុទាំងនេះ នឹងថយចុះយ៉ាងលឿនពាក់ពាន់ ទៅនឹង អាយុវាចាស់* (Mannetje and R.M. Jones(Editors)1992) ។

*-ជាប្រភេទស្មៅដែលមានដើមធំ ស្លឹកទន់ល្អ និងមានជាតិផ្អែមនៅផ្នែកបណ្តូលនៃដើមរបស់វា ពេល វាមានអាយុ ៤៥-៦០ថ្ងៃ បន្ទាប់ពីដាំ ។*

*-ជាប្រភេទដំណាំចំណីសត្វដែលមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដុះនៅស្ទើតែគ្រប់ប្រភេទដី តាមការ អនុវត្តជាក់ស្តែង ឃើញវាដុះបានល្អនៅលើប្រភេទដីល្បាយខ្សាច់ និង ដី ល្បាប់តាមដងទន្លេ ។*

*-ដំណាំចំណីសត្វប្រភេទនេះ គេដាំវាដោយដើមហើយវាងាយនិងដុះលូតលាស់វាជាប្រភេទដំណាំដែល បែកខ្នែងល្អ ជាពិសេសក្រោយពេលកាត់លើកទី១ ខ្នែងរបស់វា បែកពី២០-៣០ដើមក្នុង១គុម្ព ។*

*ប្រការដែលគួរចងចាំ ដើម្បីអោយគុណភាពរបស់វាធានាក្នុងការកាត់ផ្តល់បានល្អ យើងចាំបាច់ត្រូវ បន្ថែមនូវជីដល់ដំណាំអោយបានរៀងរាល់ឆ្នាំជាពិសេសជីលាមកសត្វហើយជាងនេះទៅទៀត គឺយើងត្រូវកាត់វាផ្តល់ ជាចំណីសត្វ មិនត្រូវទុកវាអោយឡើងដើមខ្ពស់ព្រោះដើមវារឹងនៅពេលចាស់សត្វមិនសូវស៊ី ។*



ពូជស្មៅ ដំរី ( Elephan grass)

ខ-ពពួកលេហ្គឹម ( Legumes )

ពូជ ស្តាយឡូ ១៨៤ (Styio-184)

ពូជស្តាយឡូ ជាប្រភេទដំណាំចំណីសត្វដែលស្ថិតក្នុងប្រភេទលេហ្គឹម ឬអាចហៅបានថាជាពពួកឃាសជាតិអំ បូស ណ្តែក។ ដំណាំប្រភេទនេះគេដាំសម្រាប់កាត់ផ្តល់អោយសត្វស៊ីរួមមាន សត្វទំពារអៀងទូទៅ និង ជាចំណីសំខាន់ សម្រាប់ ជ្រូក មាន់ និងត្រីផងដែរ។

ពូជនេះក្នុងអំឡុងឆ្នាំ ១៩៨៦បាននាំមកដាំនៅស្ថានីយ៍ចិញ្ចឹមគោពូជភ្នំតាម៉ៅ ដែលប្រើសម្រាប់ជាចំណីគោ មិន មែន ជាលក្ខណៈផ្សព្វផ្សាយពូជទេ។

ក្នុងអំឡុង ឆ្នាំ១៩៩៧-១៩៩៨ ត្រូវបានណែនាំអោយប្រើ និង ផ្សព្វផ្សាយដល់កសិករ នៅតាមបណ្តាខេត្តក្នុង ប្រទេសមុនគេ ដោយគំរោង CAAEP សហការណ៍ជាមួយនាយកកដ្ឋានផ្សព្វផ្សាយកសិកម្ម និងនាយកដ្ឋានផលិត កម្ម និង បសុព្យាបាល ។

-ស្តាយឡូយើងអាចដាំវានៅស្ទើតែគ្រប់ប្រភេទដី ដូចជាដីមានជីជាតិល្អ មធ្យម និង ដីមិនសូវសំបូជី ជាតិ តែវាមិនត្រូវការនូវប្រភេទដីដែលមានជាតិអាស៊ីតខ្ពស់។

-ចំណីសត្វប្រភេទនេះគេដាំវាបានល្អដោយប្រើគ្រាប់ ហើយគ្រាប់វាត្រូវការដាស់ដំណេកដោយប្រើទឹក ក្តៅ ៨0 $^{o}$C ស្រុះវារយៈពេល ៣-៥នាទី ហើយសំងិលវាក្រោមម្លប់អោយស្ងួតទើបដំណើរការដាំ ។

-គេអាចដាំស្តាយឡូបានដោយសាបពេញផ្ទៃចំការ ដាំជាជួរឆ្លាស់ជាមួយស្មៅ ឬដាំនៅចន្លោះដំណាំ ។

-គេអាចកាត់វាផ្តល់អោយសត្វស៊ីស្រស់ៗ និងក៏អាចហាលស្ងួតវាផលិត ជាម្សៅកន្ទក់ ផ្តល់អោយសត្វ

-ស្តាយឡូជាចំណីដែលគេចាត់ទុកជាចំណីផ្តល់ជាតិប្រូតេអ៊ីនខ្ពស់ដល់សត្វ ទំពារអៀង និងជ្រូក

-ស្តាយឡូជាទូទៅ វាមានកំរិតជាតិអាស៊ូត ( N ) ១,៥-៣% ហើយកំរិតសារធាតុស្ងួតដែលរលាយ (DM digestibility)៦0-៧0% ពេលដែលស្ងួតវានៅខ្ចី ។ កំរិតនេះនិងមានការប្រែប្រួលទៅតាមអាយុ និងដីកន្លែង ដាំ ( PlantResources of South Asia 1992 ) ។



ពូជ ស្តាយឡូ (Styio-184)

ឱុសមិនធុស ( Desmanthus )

ឱុសមិនធុស ជារុក្ខជាតិស្ថិត ពពួកលេហ្គីមអំបូរសណ្តែក ហើយពូជនេះណែនាំ និង ផ្សព្វផ្សាយនៅតាមបណ្តាខេត្ត នៃប្រទេសកម្ពុជាតាមរយៈគំរោង CAAEP សហការជាមួយនាយកដ្ឋានផ្សព្វផ្សាយអំឡុងឆ្នាំ ១៩៩៧-១៩៩៨ បច្ចុប្បន្នពូជនេះបានបន្សល់ទុកនៅក្នុងខេត្តកំពង់ចាម បាត់ដំបង កំពត ក្នុងចំនួនតិចតួច ។

ចំណីសត្វមួយប្រភេទនេះគេចាត់ចូលជាចំណីផ្តល់នូវជាតិប្រូតេអ៊ីនខ្ពស់ ដែលប្រើសម្រាប់លាយជាមួយ ស្មៅផ្តល់អោយគោ ក្របី សេះ ចៀម ជាពិសេសពពែ ។

លក្ខណះពិសេសរបស់វាៈ

-ដាំវាដោយគ្រាប់ តែគ្រាប់វាមានសំបកក្រាស់ ដូច្នេះមុនដាំត្រូវស្រុះ និងទឹកក្តៅដូចគ្រាប់ ស្តាយ ឡូ ១៨៤ដែរ ។

- នៅកម្ពុជាឃើញថា វាអាចដុះលូតលាស់ល្អលើប្រភេទដីក្រហម ដី ឥដ្ឋខ្មៅ និងប្រភេទដីល្បប់ តាមដងទន្លេមេគង្គផងដែរ ។

-ឱុសមិនធុស សមស្របនិងប្រភេទដំណាំចំណីសត្វសម្រាប់កាត់ផ្តល់អោយសត្វ

-ដំណាំចំណីសត្វនេះដាំនៅប្រទេសកម្ពុជាវាផលិតគ្រាប់បានល្អហើយគ្រាប់វាធំងាយប្រមូលទុក

-ឱុសមិនធុសមានកំរិតអាសូត ( N )ខ្ពស់ នៅស្លឹករបស់វាមានរហូតដល់ទៅ ៣,៦%វាជាចំណី ផ្តល់ នូវសារធាតុចិញ្ចឹមខ្ពស់សម្រាប់សត្វ ( PlantResources of South Asia 1992 ) ។

-ឱុសមិនធុសដើមវារឹងប្រសិនបើយើងពន្យាពេលប្រមូលផល ស្លឹកវាថយចុះ មែកចាស់ៗកើនឡើង ដូចនេះវាមានផលលំបាកដល់ការរំលាយអាហាររបស់សត្វ ។

-គេអាចប្រើស្លឹកស្រស់ៗសម្រាប់ផ្តល់អោយសត្វ ឬអាចហាលវាហើយកិនវាជាម្សៅចំណីសត្វ ។

បច្ចុប្បន្នដំណាំចំណីសត្វប្រភេទនេះ ពុំសូវមានដាំទេ ព្រោះពូជរបស់វាមានចំនួនតិច ហើយការផ្សព្វផ្សាយ ទៅដល់កសិករ ក៏ពុំទាន់បានដំណើរការបានល្អនៅឡើយ ។



**ពូជ ឪសមិនធុស** ( Desmanthus )

**គ-ពពួកលហ្គីមដើមឈើ ( Tree Legum )**

កន្ធថេត **( Leucaena )**

កន្ធំថេតមានប្រភេទពូជខុសៗ គ្នាជាច្រើនតែវាស្ថិតក្នុងគ្រួសារតែមួយ ហើយត្រូវបានគេចាត់ថ្នាក់ជាដំណាំចំណីសត្វ ដែលស្ថិតក្នុងពពួកលេហ្គីមដើមឈើ ។ រុក្ខជាតិប្រភេទនេះកសិករទំលាប់ដាំធ្វើជារបងនៅជុំវិញ ដី ភូមិ ឬ ដីចំការ ហើយស្លឹកខ្ចីៗគេប្រើធ្វើជាបន្លែស្រស់សម្រាប់មនុស្ស ។

បច្ចុប្បន្នដោយមានការកែប្រែប្រពន្ធ័ចំណីសត្វ កន្ធំថេតត្រូវបានគេចាត់ទុកជាដំណាំចំណីសត្វដែលមាន លក្ខណៈល្អប្រសើរ ជាពិសេសសម្រាប់សត្វក្រពះថត មានគោ ក្របី ពពែជាដើម ។ ចំពោះសត្វជ្រូកគេអាចផ្តល់អោយ វាស៊ីក្នុងកំរិតតិចតួច ព្រោះស្លឹកកន្ធំថេតមានជាតិពុលម្យ៉ាង ឈ្មោះ មីណូស៊ីន ( Minosine ) អាចធ្វើអោយមានការ ពុល ឬបង្កបញ្ហាដល់ពពួកសត្វក្រពះទោល (Werner W.Stür and Peter M.Horne ) ។

លក្ខណៈពិសេសរបស់កន្ធំថេតៈ

-ជាប្រភេទដំណាំចំណីសត្វដែលអាចដាំដោយគ្រាប់ ផ្ទាល់ ឬដាំដោយកូនបណ្តុះ

-ជាប្រភេទដំណាំចំណីសត្វដែលមានអាយុកាលវែង មានកំពស់ដើមខ្ពស់ និងទំហំដើមធំ

-ជាប្រភេទដំណាំដែលមានស្លឹកពណ៌បៃតងខ្ចីជានិច្ច គ្រប់រដូវ ឬមានរយៈពេលជ្រុះស្លឹកខ្លី

-វាមានលក្ខណៈពិសេសម្យ៉ាង គឺស្លឹកវាខ្ចីជានិច្ចប្រសិនបើយើងកាត់មែករបស់វាបានត្រឹមត្រូវ

-វាមានការដុះលូតលាស់ល្អនៅលើប្រភេទដីែ់ដលមានជីជាតិ និង មិនដុះនៅលើដីជាំទឹក ដីអាស៊ីត

-ការដាំកន្ធំថេតនៅក្នុងប្រទេសកម្ពុជាយើងគឺ សមស្របនឹងអាកាសធាតុ ទឹក ដីហើយវាដុះបានល្អ

-ចំពោះពូជដែលបានដាំក្នុងស្រុក និងពូជនាំចូលមួយចំនួនដូចជា K584 និង K636វាមានលទ្ធភាព ក្នុងការផលិតគ្រាប់ពូបានល្អ ពូជ K584 និង K636វាផលិតស្លឹកបានច្រើនជាងពូជក្នុងស្រុក តែផលិតគ្រាប់បានតិច ។

-ជាប្រភេទចំណីល្អសម្រាប់សត្វ មានកំរិតអាសូតក្នុងស្លឹកពី៣-៤%សារធាតុរលាយ៦០-៧០% ។



កូនកន្ទ្រថេតបណ្តុះ



ដាំកូនកន្ទ្រថេត



កន្ទ្រថេតកំពុងលូតលាស

គ្លីរីស៊ីដ្យា ( **Gliricidia** )

គ្លីរីស៊ីដ្យា ជាពូជលេហ្គីមដើមឈើមួយប្រភេទ ក្នុងចំណោមប្រភេទដទៃៗទៀតដែលផ្តល់ស្លឹកច្រើន សម្រាប់ជាចំណី សត្វទូទៅ ស្លឹកវាសមស្របទៅនិងចំណីសម្រាប់ ពពែ ចៀម និង អាចធ្វើជាចំណីគោក្របី ហើយវាមិនល្អទេ សម្រាប់ការផ្តល់អោយពពួកសត្វក្រពះទោល ។

លក្ខណៈពិសេសរបស់គ្លីរីស៊ីដ្យាៈ

-គេអាចដាំវាបានដោយប្រើគ្រាប់ និងជាការងាយស្រួលគឺ ការដាំដោយដើមបណ្តុះមានការដុះលូតលាស់លឿនជាងការដាំដោយគ្រាប់ ។

-គ្លីរីស៊ីដ្យាអាចដុះលូតលាស់បានគ្រប់រដូវ ពិសេសរដូវប្រាំងវាមានស្លឹកខ្ចីល្អបើយើងកាត់វាបានត្រឹមត្រូវ

-វាអាចដុះលូតលាស់បាននៅលើដីដែលមានជីជាតិល្អ និង មធ្យម

-ស្លឹករបស់វាជាធម្មតាមានក្លិនក្រពុលឈ្ងុលៗ ជាហេតុនាំអោយសត្វមិនចង់ស៊ីពេលកាត់មកភ្លាមៗ តែយើងអាចកាត់ហើយហាលថ្ងៃមួយស្រពាប់ទើបផ្តល់អោយសត្វស៊ីជាការល្អ។

-គេអាចផ្តល់គ្លីរីស៊ីដ្យាលាយជាមួយស្មៅឬចំបើងផ្តល់ជាចំណីគោនៅរដូវប្រាំងក្នុងកំរិត ១/៣ ដើម្បីជា ការបង្រៀនសត្វអោយស៊ីផង និង ដើម្បីអោយសត្វទទួលបាននូវអាហារូបត្ថម្ភ តាមរយៈស្លឹកស្រស់ផងដែរ ។

-ស្លឹកខ្ចីរបស់គ្លីរីស៊ីដ្យាជាទូទៅមានកំរិតអាស៊ូត ( N ) ពី៣-៥% ហើយសារធាតុស្ងួតដែលរលាយវាស្ថិតនៅចន្លោះ ពី ៤៨-៧៧% (Werner W.Stür and Peter M.Horne ) ។

ដូចនេះគ្លីរីស៊ីដ្យា ជាប្រភេទដំណាំចំណីសត្វល្អបង្គួរ ហើយក៏ជាប្រភេទដំណាំចំណីដែលអាចផ្គត់ផ្គង់សត្វនៅរដូវប្រាំង ដែលខ្វះខាតចំណីនោះបានល្អប្រសើរផងដែរ ។



គ្លីរីស៊ីដ្យា ( Gliricidia )

## ៥.ការដាំដំណាំចំណីសត្វ

ដើម្បីភាពជោគជ័យក្នុងការដាំដំណាំចំណីសត្វ មានកត្តាជាច្រើនដែលសំរួលអោយយើងឈានទៅដល់គោលដៅមួយយ៉ាងពិតប្រាកដ កត្តាទាំងនោះមានៈ ការរៀបចំទីតាំងការរៀបចំពូជពេលវេលា នៃការចាប់ផ្តើមការយល់ដឹងពីបច្ចេកទេសដាំដុះ និង ការរៀបចំសំភារៈដាំដុះ ហើយកត្តាសំខាន់មួយទៀតគឺបច្ចេកទេសក្នុងការថែទាំ ។

### ៥.១-ការជ្រើសរើសទីតាំងដើម្បីដាំ

*ក-ការកំណត់តំបន់ដែលត្រូវចាប់ផ្តើមដាំដុះ*

ប្រពន្ធ័នៃការចិញ្ចឹមសត្វតាមបែបលក្ខណៈគ្រួសារនៅប្រទេសកម្ពុជាជួបប្រទះនូវផលលំបាកខុស១ គ្នា គឺតំបន់ខ្លះ លក្ខណៈទីតាំងក្នុងការចិញ្ចឹមធំទូលាយ ហើយសំបូរទៅដោយធនធានចំណីសត្វជាលក្ខណៈធម្មជាតិដូច នេះផលលំបាករបស់ពួកគេគឺកង្វះការយល់ដឹងទៅលើការកំណត់អំពីគុណភាពចំណីសម្រាប់សត្វ តែគេពុំមានបញ្ហា ក្នុង ការខ្វះខាតបរិមាណចំណីឡើយ ។ តំបន់ដែលមានដូចករណីខាងលើនេះភាគច្រើនកើតមាននៅតំបន់ ខ្ពង់រាបដែលមាន ជួរភ្នំ និងតំបន់ព្រៃមួយចំនួននៃភាគឥសាន្តនៃប្រទេសកម្ពុជា ។

ករណីចាំបាច់ក្នុងការជួយពួកគេក្នុងស្ថានភាពបែបនេះសំខាន់គឺៈ

-ណែនាំអោយគេបានស្គាល់ អំពីអ្វីជាធនធានចំណីសត្វមាននៅក្នុងតំបន់ដែលគេរស់នៅ

-ជួយអោយពួកគេចេះកែច្នៃ ប្រើប្រាស់វាអោយបានសមស្រប និងអោយអស់លទ្ធភាពដែលគាត់មាន

-ជួយកែទំលាប់បន្តិចម្តង១យ៉ាងណាអោយគាត់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការពង្រីកផលិតកម្មសត្វដោយប្រើប្រាស់ធនធានធម្មជាតិរបស់គាត់អោយគង់វង្ស ជៀសវាងបានការខូចខាតនូវបរិស្ថានចំណីធម្មជាតិ ។

តំបន់ដែលមានលក្ខណៈដូចខាងលើនេះប្រសិនបើយើងបំផុសអោយមានការដាំដំណាំចំណីសត្វនោះភាពជោគជ័យមានតិចតួចណាស់ហើយភាពបរាជ័យមានលក្ខណៈធំធេងជាង ។

ដូចនេះតំបន់ដែលយើងចាប់ផ្តើមគួរតែ ជាកន្លែងដែលជួបប្រទះនូវផលលំបាកដូចជា ៖

-ជាតំបន់ដែលចិញ្ចឹមសត្វច្រើនហើយមានបញ្ហាលំបាកជាមួយនិងចំណីសត្វ ខ្វះចំណីទូទៅក្នុងរដូវប្រាំង

-ជាតំបន់ដែលមានផ្ទៃដីសម្រាប់វាលស្មៅចំណីសត្វធម្មជាតិតិច

-ជាតំបន់ដែលសំបូរទៅដោយវាលទំនាប សម្រាប់ដាំដំណាំ ឬវាលស្រែ

-ជាតំបន់ដែលកសិករម្ចាស់សត្វភាគច្រើន ចេញទៅរកចំណីសម្រាប់សត្វរបស់គាត់នៅតំបន់ឆ្ងាយៗ ឬមិនមានកំលាំងពលកម្មគ្រប់គ្រាន់ក្នុងការរកចំណីសត្វ ។

សរុបសេចក្តីទៅយើងគួរចាប់ផ្តើមបំផុស ឬផ្សព្វផ្សាយអោយមានការដាំដំណាំចំណីសត្វ នៅតំបន់ដែលយើង សិក្សាឃើញថា មានការបាត់បង់ នូវតុល្យភាពរវាងចំនួនសត្វ និងបរិមាណចំណីដែលត្រូវផ្តល់អោយសត្វ ហើយ ជា ពិសេស ក្នុងពេលបច្ចុប្បន្ន កំពុងកើតមានការលំបាកយ៉ាងធ្ងន់ធ្ងរ នៅតំបន់មួយចំនួននៃវាលទំនាបព្រោះតំបន់នេះមានការពង្រីក ការដាំដុះដំណាំកសិកម្មច្រើន ការពង្រីកផ្ទៃដីដាំដុះកាន់តែធំធេងដូច នេះវាលស្មៅត្រូវរួមតូច ពិបាកក្នុងដំណើរការ ចិញ្ចឹមសត្វជាពិសេស ការចិញ្ចឹម គោ ក្របី ។

*ខ-ការកំណត់លក្ខណៈដីសម្រាប់ដាំដំណាំចំណីសត្វ*

ការជ្រើសរើសប្លង់ដីសម្រាប់ដាំដំណាំចំណីសត្វបានសមស្រប វាជាផ្នែកមួយជួយអោយដំណើរការដាំដំណាំចំណីសត្វ មានលទ្ធផលល្អ ។ គេអាចកំណត់យកនូវកន្លែងដាំបានច្រើនសណ្ឋាន ដូចជា ប្លង់ដី ភូមិ មានដីមុខនិង ដីក្រោយផ្ទះ ដីចំការជិត ឬ ឆ្ងាយដាច់ពីផ្ទះហើយអាចគ្រប់គ្រងបាន ឬ ដីចន្លោះរងចំការដំណាំហូបផ្លែ ដែលដើមរបស់វា នៅតូចៗ និងអាច ជាដីទួល នៅតាមវាលស្រែ ។ ទោះជាដីស្ថិតក្នុងស្ថានភាពណាក៏ដោយតែយើងគួតែជ្រើសរើសនូវដីតាមគោលការណ៍បច្ចេកទេស ដូចខាងក្រោមៈ

-ជាដីទួលមិនលិចទឹក រយៈពេលយូរ ឬជាដីដែលមិនជាំទឹកជាប្រចាំ

- ជាដីដែលដំណាំមានលទ្ធភាពទទួលពន្លឺគ្រប់គ្រាន់ ដើម្បីដុះលូតលាស់

- មិនមែនជាដីវាលស្មៅធម្មជាតិរួមសម្រាប់លែងគោ ក្របីអោយស៊ី ដោយគ្មានការគ្រប់គ្រង

-ជាដីដែលមិនមានការផ្លាស់ប្តូរមុខដំណាំរយៈពេលខ្លី រៀងរាល់ឆ្នាំ

-ផ្ទៃដីដែលសំរេចដាំដំណាំចំណីសត្វ ត្រូវមានការចូលរួមសំរេចពីកសិករជាម្ចាស់ដោយស្ម័គចិត្ត

ជាបទពិសោធន៍ក្នុងការអនុវត្តន៍ជាក់ស្តែង យើងឃើញថាមានដីមួយចំនួនដូចជា ដីដែលកសិករ ធ្លាប់ព្រោះស្រូវ ដាំពោត ឬថែរក្សាស្មៅក្នុងស្រុកសម្រាប់ជាចំណីគោ ក្របី ដីធ្លានៅជុំវិញទ្រុងសត្វ និងដីដែលទំនេរមិនសូវមានការប្រើប្រាស់ឬដាំដុះដំណាំ សុទ្ធតែជាទីតាំងដែលល្អសម្រាប់ការចាប់ផ្តើមដំណើរការដាំដំណាំចំណីសត្វ ដោយមានការចូល រួមពីកសិករ ក៏ដូចជាទីតាំងដ៏ល្អសម្រាប់ដំណើរការផ្សព្វផ្សាយអោយកសិករមានការយល់ដឹង និង ឈានទៅដល់ការ កែប្រែទំរង់ប្រពន្ធ័ចំណីសត្វ ។

### *គ-ការរៀបដីដើម្បីដាំដំណាំចំណីសត្វ*

ការរៀបចំដីវាជាដំណាក់កាលមួយក្នុងការចាប់ផ្តើមដាំដុះដំណាំចំណីសត្វ ការងារនេះគេចែកជាបីដំណាក់កាលរួមមានៈ

-ការធ្វើរបងការពារចំការដំណាំចំណីសត្វមុនពេលដាំ

-ការភ្ជួរដាស់ដី មុនពេលដាំដំណាំចំណីសត្វ

-ការរៀបចំដីសំរេចនៅពេលដំណើរការដាំដំណាំចំណីសត្វ

ឆ្លងកាត់ដំណាក់កាលទាំងបីខាងលើ នោះនឹងជួយអោយដំណើរការដាំមានភាពងាយស្រួលមានសុវត្ថិភាពដល់ដំណាំចំណីសត្វជាផ្នែកមួយដែលជួយអោយដំណាំចំណីសត្វមានការលូតលាស់បានល្អ និងហើយវាបានជួយសំរួលដល់ដំណើរការគ្រប់គ្រងក្រោយពេលដាំ។

*ការធ្វើរបងការពារ*

ដើម្បីជៀសវាងបាននូវការខូចខាតដំណាំចំណីសត្វក្រោយពេលដាំដុះ និង ដើម្បីអោយការទទួលផលពីដំណាំបានសមស្រប តាមអាយុកាលរបស់វា កាធ្វើរបងការពារដំណាំចំណីសត្វដែលសម្រាប់កាត់ និងផ្តល់អោយ សត្វជាមុន វាមានសារៈសំខាន់ដូចជាៈ

-ការពារបានពីការបំផ្លាញរបស់ហ្វូងសត្វនៅរដូវប្រាំងដែលកសិករភាគច្រើនលែងសត្វអោយដើរស៊ីសេរី

-បង្កើននូវការងារគ្រប់គ្រង និង ធ្វើអោយកសិករយល់កាន់តែច្បាស់ពីសារៈសំខាន់នៃដំណាំចំណីសត្វ

-វាសមស្របទៅនិងប្រពន្ធ័ចិញ្ចឹមសត្វជាលក្ខណៈគ្រួសារពាក់កណ្តាលលែងពាក់កណ្តាលបង្ខាំង

-ពិសេសវាជួយអោយកសិករទទួលបានជោគជ័យក្នុងដំណើរការដាំដុះដំណាំចំណីសត្វ។

ជាទូទៅរបងត្រូវបានរៀបចំទៅតាមស្ថានភាព ជីវភាព និងលទ្ធភាពដែលកសិករអាចធ្វើទៅបាន ដោយប្រើ ប្រាស់នូវធនធានក្នុងភូមិ ដើម្បីជៀសវាងការចំណាយធំធេង និងបង្កផលលំបាក ឬប៉ះពាល់ដល់ជីវភាពរបស់កសិករ សំភារៈទាំងនេះរួមមានៈ

-បង្គោលរបង អាចប្រើកូនឈើ គល់ឬស្សីស្រុក ដែលមានប្រវែង១,៧-២ម៉ែត្រ

-របាររអាចជ្រើសរើសយកដើមឬស្សីមែកឈើតូចៗ ឬ សំរះបន្លាផ្សេងៗលៃយ៉ាងណាវ៉ាយជារបា អោយបានកំពស់១,៣-១,៥ម។

-ប្រសិនបើប្រើកូនឈើឬ ឬស្សីជារបាយើងអាចវ៉ាយក្នុងចន្លោះ០,៣ម ពីរបាមួយទៅរបាមួយ

-របងត្រូវមានការត្រួតពិនិត្យជាប្រចាំដើម្បីជៀសវាងមានការបំផ្លាញពីកត្តាខាងក្រៅ

ការភ្ជួរដាស់ដី

ការភ្ជួរដាស់ដីគេចាប់ផ្តើមភាគច្រើននៅពេលដែលមានភ្លៀងធ្លាក់ ដើមឆ្នាំកំរិតទឹកភ្លៀង បានស្រោចស្រពជោគជាំដី កូនស្មៅចង្រៃចាប់ផ្តើមដុះ ហើយដីមានសភាពហើមល្មមនិងភ្ជួរបាន។

សារៈប្រយោជន៍ក្នុងការងារដាស់ដីគឺៈ

-ជួយក្នុងការកែទំរង់ដីពីហាប់ណែន អោយមានសភាពធូរល្អ

-ភ្ជួរដើម្បីហាលដី ឬសំលាប់ពពួកស្មៅចង្រៃពេលវាចាប់ផ្តើមដុះលើកដំបូង

- ងាយស្រួលក្នុងការបំបែកលំអិតពេលរៀបចំដីសំរេច និង សំរួលដល់ការកប់គ្រាប់ដំណាំចំណីសត្វ

-ការភ្ជួរដាស់ដីដើម្បីជួយអោយទឹកភ្លៀងងាយជ្រាបចូលទៅក្នុងស្រទាប់ដីផ្នែកខាងក្រោមបានសព្វល្អ

-បានបង្កប់ស្មៅ និង កំទេចកំទី ឬជីលាមកសត្វទៅផ្នែកនៃស្រទាប់ដីដាំដុះដើម្បីអោយវារលួយផុយ បង្កើនគុណភាពដី។

ដូចនេះការភ្ជួរដាស់ដីចាំបាច់ធ្វើឡើង រយះពេលយ៉ាងតិច១០ថ្ងៃ មុនការរៀបចំដីសំរេច។

***ការរៀបចំដីសំរេចនៅពេលដំណើរការដាំដំណាំចំណីសត្វ***

ការរៀបចំដីសំរេចគឺជាដំណាក់កាលចុងក្រោយនៃការរៀបចំដីសកម្មភាពសំខាន់ៗដែលត្រូវដំណើរការមាន:

-ភ្ជួររំប្រែត្រឡប់ដី ដែលបាន ដាស់រួចពីមុនមក អោយបានសព្វល្អ

-រាស់បំបែកដីអាចម៍បំណាស់ ពង្រាបវាអោយស្មើល្អ និងរើសស្មៅ ដែលនៅសេសសល់អោយស្អាត

-ឆ្វូតគន្លងសម្រាប់បង្ហូរទឹក បង្កាទុកបង្ហូរនៅពេលមានភ្លៀងធ្លាក់ច្រើនជៀវាងមានដក់ទឹកក្នុងចំការ

-បែងចែកផ្ទៃដីជាជួរតំរូវតាមចំនួននៃប្រភេទគ្រាប់ពូជ ធ្វើអោយច្បាស់ថា តើមួយប្រភេទពូជមាន ប៉ុន្មានជួរ (ធ្វើយ៉ាងនេះក្នុងករណីយើងដាំជាជួរឆ្លាស់ពូជ)។

-ឆ្វូតចង្អូរដោយប្រើចបជុំរះក្នុងជុំរៅ 0,0៣ម អោយត្រង់ល្អទៅតាមជួរដែលបានលៃលករួចមកហើយដើម្បីជាកន្លែងកប់គ្រាប់ដាំ។

ក្នុងករណីយើងចង់ប្រើជីលាមកសត្វឬជីកំប៉ុសសម្រាប់ជាជីទ្រាប់បាតអាចដាក់វានៅពេលដែលយើងចាប់ផ្តើមរាស់បំបែកដី ព្រោះនៅពេលនោះជីមានការច្របល់បានសព្វល្អ និងវាកប់ចូលទៅក្នុងជំរៅដីដាំដុះ ហើយវារក្សា គុណភាពដីបានល្អជាងការដាក់នៅផ្នែកខាងលើនៃផ្ទៃដី។

ការរៀបចំដី ជាទូទៅយើងគួរតែធ្វើអោយសមស្របទៅ នឹង លក្ខណៈរបស់សណ្ឋានដីដោយលៃយ៉ាងណារក្សាបាននូវ លក្ខណៈបរិស្ថាន និងទំរង់លក្ខណៈរបស់ដី ដោយសមស្របតាមលក្ខណៈបច្ចេកទេស ក្នុងការប្រើប្រាស់ដី។



រៀបចំមុនពេលដាំ

**៥.២-ការរៀបចំពូជដំណាំចំណីសត្វដើម្បីដាំ**

ពូជជាកត្តាសំខាន់ក្នុងការកំណត់នូវភាពជោគជ័យក្នុងដំណើរការដាំដុះចំណីសត្វ ។ ដើម្បីសំរេចអោយបាននូវដំណើរការនេះយើងចាំបាច់ ត្រូវយល់ដឹងនូវការងារមួយចំនួនដូចជា ការជ្រើសរើស និងប្រើប្រាស់ពូជ របៀបពិនិត្យ គុណភាពពូជ លក្ខណៈជីវសាស្ត្ររបស់ប្រភេទពូជ របៀបសាកល្បងគ្រាប់ពូជ និងបរិមាណគ្រាប់ពូជដែលត្រូវដាំ។

***ក-ការជ្រើសរើសពូជ ដំណាំចំណីសត្វ ដើម្បីដាំ***

យើងឃើញថាមានប្រភេទនៃដំណាំចំណីសត្វ ច្រើនខុសៗគ្នា ហើយទំរង់លក្ខណៈតំបន់ដាំដុះ និងចំណង់ ចំណូល ចិត្តរបស់អ្នកដាំក៏ខុសៗគ្នា ។

ហេតុនេះ ដើម្បីតំរូវទៅលើលក្ខណៈទាំងអស់អោយបានសមស្របចាំបាច់អោយយើងយល់ដឹងពីរបៀប ជ្រើសរើសពូជ។

វាមានលក្ខណៈមួយចំនួនដែលជួយអោយយើងជ្រើសរើសដំណាំចំណីសត្វមកដាំបានសមស្រប +

-ជ្រើសរើសតាមវិធីសាស្ត្រដាំដុះ និង តំរូវការប្រើប្រាស់

-ជ្រើសរើសតាមអាកាសធាតុ និង ប្រភេទដីដែលត្រូវដាំ

-ជ្រើសរើសតាមទំរង់នៃការដុះលូតលាស់របស់ដំណាំចំណីសត្វ

-ជ្រើសរើសតាមចំណង់ចំណូលចិត្ត និងសារៈប្រយោជន៍

ឧទាហរណ៍

| រើសតាមវិធីសាស្ត្រដាំដុះ និងតំរូវការប្រើប្រាស់ | រើសតាមអាកាសធាតុ និង ប្រភេទដីត្រូវដាំ | រើសតាមទំរង់នៃការលូតលាស់របស់ដំណាំចំនីសត្វ | រើសតាមចំណង់ចំណូលចិត្តរបស់អ្នកដាំដំណាំ ចំនីសត្វ | ប្រភេទពូជដំណាំ |
|---|---|---|---|---|
| -ដាំសម្រាប់កាត់ផ្តល់អោយសត្វស៊ី | -ដាំនៅតំបន់រដូវប្រាំងវែង | -ប្រភេទកំពស់ដើមខ្ពស់ | -ងាយស្រួលច្រូតកាត់ និងធន់ទ្រាំការច្រូត ដើមនិងស្លឹកទន់ល្អ មានការលូតលាស់លឿន | បាស៊ីលីស |
| -ដាំជាប្លង់សម្រាប់លែងសត្វអោយស៊ី | -ដាំនៅតំបន់រដូវប្រាំងខ្លី | -ប្រភេទកំពស់ដើមមធ្យម ទាប រឹងមាំ ធនទ្រាំការស៊ីច្រើនរបស់សត្វ | -ផ្តល់ទិន្នផលខ្ពស់ | ទុល លី |
| -ដាំជារបងរស់ | -ដាំនៅតំបន់អាកាសធាតុត្រូពិកសើម | -ប្រភេទលេហ្គឹមដើមឈើ អាចដាំដោយដើម ធន់ទ្រាំការច្រូតកាត់ | -គុណភាពចំណីល្អសម្រាប់សត្វ | គ្លីរីស៊ីដ្យា |
| -ដាំកែលំអរដី | -ដាំនៅលើដីមានការថយចុះដីជាតិ | -ប្រភេទលេហ្គឹម | -សត្វចូលចិត្តស៊ី | ស្តាយឡូ |
| -ដាំទប់ស្កាត់ហូរច្រោះដី | -ដាំលើប្រភេទដី មានដី ជាតិល្អ ដីចំណោត | -ប្រភេទលេហ្គឹមដើមឈើ | -ងាយថែរក្សាមិនមានការបំផ្លាញពីកត្តាចង្រៃ | កន្ទំថេត |
| -ដាំជាចំណីបន្ថែមដល់សត្វ | -ដាំលើដីអាស៊ីតល្អម | -ដើមឈរត្រង់ មិនដួល | -កាត់ហើយឆាប់លាស់ឡើងវិញ | ប៉ាស្ពាលូម |

*ខ-តារាង កំណត់សំគាល់ការប្រើប្រាស់ពូជ*

| ឈ្មោះពូជ | ដាំដោយគ្រាប់ផ្ទាល់ | បំបែកគល់ | ដាំដោយគ្រាប់បណ្តុះ | ដាំដោយប្រើដើម |
|---|---|---|---|---|
| ពពួកស្មៅ | | | | |
| **ហ្គាមបា** (Gamba) | - | - | - | - |
| **បាស៊ីលីស** (Basilis) | - | - | - | - |
| **ម៉ារ៉ាន់ឌូ១៥០៣រានដុប** | - | - | - | - |
| **មុលឡាតូ** (Mulato) | - | - | - | - |
| **ប៉ាស្ពាលូម** (Paspalum) | - | - | - | - |
| **ហ្គីនី** (Guinea) | - | - | - | - |
| **រូស៊ីក្រាស** (Ruziziensis) | - | - | - | - |
| **ឃីងក្រាស់** (King grass) | - | - | - | - |

| | | | | |
|---|---|---|---|---|
| **ស្មៅដំរី** (Elaphan grass) | - | - | - | - |
| **ពពួកលេហ្គឹម** | | | | |
| **ទ្រឹចាន់ត្រាទរយចហាន តរាប** | - | - | - | - |
| **មន** (Mulbary) | - | - | - | - |
| **កន្ទួចេត 9ឡេ្ប០ុចានោប** | - | - | - | - |
| **គ្លីរីស៊ីតដ្យា** (Gliricidia) | - | - | - | - |
| **ស្តាយឡូ** (Stylo) | - | - | - | - |
| **ឪសមិនធុស** | - | - | - | - |

**ដាំបានល្អ - អាចដាំបាន -មិនអាចដាំបាន**

*គ-ការយល់ដឹងពីគ្រាប់ពូជដំណាំចំណីសត្វ*

គ្រាប់ពូជភាគច្រើនជាប្រភពដើមនៃ ការបង្កបង្កើតជាប្រភេទពូជដំណាំចំណីសត្វ ដែលមានពពួកស្មៅស្ថិតក្នុងអំបូរក្រាមមីណេ និង ពពួកឃាសជាតិ អំបូរសណ្តែក ឬ រុក្ខជាតិដែលមានដើមដងដូចជាដើមឈើ ពេញលេញពួកទាំងនេះភាគច្រើនដុះលូតលាស់តាមរយៈគ្រាប់ ។

*គុណភាពគ្រាប់ពូជ:*

ការពិនិត្យពីគុណភាពគ្រាប់ពូជវាជាការងារចាំបាច់មុនពេលដំណើរការដាំ ព្រោះថាបើយើងប្រើប្រាស់នូវគ្រាប់ពូជដែលពុំមានគុណភាពនោះវានាំអោយយើងមាន ការខាតបង់ ថវិកាពេលវេលាកំលាំងពលកម្មខូចខាតនូវគំរោងការដែលយើងត្រូវអនុវត្ត ជាពិសេសបើយើងអនុវត្តជាមួយកសិករវាធ្វើអោយពួកគាត់បាត់បង់ជំនឿទុក ចិត្ត លើបច្ចេកវិទ្យាដែលយើងកំពុងផ្សព្វផ្សាយ ។

ដើម្បីជៀសវាងបាននូវប្រការនេះ យើងជាអ្នកបច្ចេកទេសត្រូវចេះពីរបៀបពិនិត្យគុណភាពពូជ:

-ដំបូងបង្អស់ត្រូវពិនិត្យពីរបៀបទុកដាក់គ្រាប់ពូជដំណាំចំណីសត្វថាត្រឹមត្រូវតាមបច្ចេកទេស ឬទេ

-ពិនិត្យពីរបៀបវិចខ្ចប់ថា មានកំរិតជិតល្អ ការពារបានពីខ្យល់ ពីពន្លឺដែរឬទេ

-ត្រូវសាកសួរអោយបានដឹងអំពីអាយុកាលពូជព្រោះវាពាក់ពន្ធ័ទៅ និងហួសកំណត់ប្រើប្រាស់និង មិនទាន់ដល់កំណត់ប្រើ ។

-ពិនិត្យរាល់ស្ថានភាពពូជ ស្ងួតល្អ ទំរង់គ្រាប់ស្មើល្អ ពណ៌សំបុរពូជ និងទំងន់ពូជផងដែរ

-ចំពោះពូជដែលមានដំណោកគ្រាប់ ឬសំបកគ្រាប់ក្រាស់ត្រូវដឹងច្បាស់ថាបានដាស់ដំណោកគ្រាប់




របៀបវិចខ្ចប់គ្រាប់ពូជ

***ដំណេកគ្រាប់ពូជ***

ជាធម្មតា គ្រាប់ពូជវាមានកំណត់ពេលចាប់ផ្ដើមប្រើប្រាស់របស់វា ព្រោះវាមានពេលវេលាដំណេកគ្រាប់៖

-ពពួកស្មៅភាគច្រើន ដំណេកគ្រាប់ ស្ថិតក្នុងអំឡុងពេល ៣-៦ ខែបន្ទាប់ពីប្រមូលផល

-ពពួកលេហ្គឹម ដែលមានសំបកគ្រាប់ក្រាស់ដំណេកគ្រាប់ ពី ៦-៨ខែបន្ទាប់ពីប្រមូលផល គ្រាប់ពូជដែលមានសំបកគ្រាប់ក្រាស់មានភាគច្រើនជាពពួកលេហ្គឹមមានដូចជា ឪសមិនធុស9ឪសេមនេតហុសប កន្ទំថេត ស្ដាយលូ ។

ដើម្បីដាស់ដំណេកគ្រាប់ពូជទាំងនេះគេមានវិធីច្រើនដូចជា៖

-កោស ឬ ខាត់សំបកគ្រាប់អោយស្ដើង

- ត្រាំគ្រាប់ក្នុងទឹកត្រជាក់រយៈពេល ១-២ថ្ងៃ ហើយស្រង់ផ្អាប់រយៈពេល២៤ម៉ោង

-ជ្រលក់គ្រាប់ទៅក្នុងសូលុយស្យុងអាស៊ីត

-ស្រុះគ្រាប់ពូជក្នុងទឹកក្ដៅដាំពុះ ២-៥វិនាទី ហើយដាក់ក្នុងទឹកត្រជាក់រហូតដល់អស់កំដៅ

-ស្រុះគ្រាប់ពូជក្នុងទឹកក្ដៅ ៨០អង្សាសេ រយៈពេល៥-១០នាទី ហើយដាក់ក្នុងទឹកត្រជាក់ដល់អស់កំដៅ

- គ្រាប់ដែលបានដាស់ដំណេកហើយត្រូវធ្វើការសំងួតដោយខ្យល់ក្រោមម្លប់លុះត្រាស្ងួតល្អ

-គ្រាប់ដែលបានដាស់ដំណេក និងសំងួតហើយ ត្រូវប្រើអោយអស់ក្នុងអំឡុងពេលពី១-១០ថ្ងៃ

វិធីដែលល្អ និងងាយស្រួលអនុវត្តក្នុងពេលដាស់ដំណេកគ្រាប់ពូជដំណាំចំណីសត្វ គឺការប្រើ ទឹក ក្ដៅ ព្រោះវាប្រើពេលខ្លី និងផ្ដល់ប្រសិទ្ធិភាពខ្ពស់ក្នុងដំណើរការអនុវត្តន៍។

*ឃ/ការសាកល្បង ដំណុះគ្រាប់ពូជដំណាំចំណីសត្វ*

ជាទូទៅក្នុងការប្រើប្រាស់គ្រាប់ពូជដំណាំចំណីសត្វទោះជាគ្រាប់ទាំងនោះមានប្រភពមកពីណាក៏ដោយយើង ចាំបាច់ត្រូវធ្វើការសាកល្បងដំណុះគ្រាប់ ។

វិធីក្នុងការធ្វើតេស្តដំណុះគ្រាប់មានពីរសំខាន់គឺៈ

១-ការសាកដំណុះគ្រាប់លក្ខណៈទូទៅ ( អនេរោល **Emergence test )**

២-ការសាកល្បងដំណុះគ្រាប់ជាក់លាក់ (Specific Emergence Test )

ការសាកល្បងទាំងពីរនេះអនុវត្តសកម្មភាពប្រហាក់ប្រហែលគ្នា តែវាមានគោលបំណងខុសគ្នាខ្លះៗ ហើយ សារៈសំខាន់របស់វា រួមមួយ គឺ ចង់ដឹងអំពីភាគរយនៃដំណុះគ្រាប់ ។

**ការសាកល្បងដំណុះគ្រាប់ជាលក្ខណៈទូទៅ ( General Emergence Test )**

ជាដំណើរការធ្វើការសាកល្បងគុណភាពដំណុះគ្រាប់ពូជ ជាលក្ខណៈទូទៅ ដោយមិនគិតពីប្រភេទដីឬបរិយាកាសជាក់លាក់នៅកន្លែងណាមួយ តែគិតទៅលើលក្ខខ័ណប្រកបដែលដំណាំចំណីសត្វអាចរស់បាន វិធីអនុវត្តគឺ ÷

-រៀបចំប្រអប់បណ្តុះ ទំហំ ១៥ សម X ២៥ សម

-ដាក់ក្រដាស់ស្តើង ឬដីខ្សាច់ហ្មត់កំរាស់ ៥ សម ពីបាតប្រអប់

-បាញ់ទឹកដោយប្រើប្រដាប់បាញ់ទឹកតូច ផ្សើមក្នុងកំរិត ៥0-៦0%

-ចាប់យកដោយចៃដន្យ នូវគ្រាប់ពូជដែលចង់បណ្តុះ ១00គ្រាប់

-ដំរៀបគ្រាប់ពូជពីលើក្រដាស់សើមឬ ឆ្នូតដីក្នុងប្រអប់ជំរៅ0,៥សមដាក់គ្រាប់ហើយលប់ដីទៅវិញ

-ក្នុងមួយប្រអប់ធ្វើយ៉ាងណាអោយបាន ១0ជួរ ហើយមួយជួរ ១0គ្រាប់ សរុប ១00គ្រាប់

-សរសេរផ្លាក កត់ត្រាពី ឈ្មោះពូជ ប្រភពពូជ លេខឡូ ថ្ងៃ ខែ ឆ្នាំធ្វើតេស្ត បិទពីលើគំរបប្រអប់

-សរសេរឈ្មោះអ្នកធ្វើពិសោធន៍ ហើយយកទៅទុកនៅកន្លែងដែលមានសុវត្ថិភាព

-ចាប់ផ្តើមរាប់ដំណុះគ្រាប់នៅថ្ងៃ១៥ បន្ទាប់ចំពោះស្មៅ និង ១0ថ្ងៃសម្រាប់ពពួកឃាសជាតិ

-មិនត្រូវយកប្រអប់ដែលបានដាក់គ្រាប់ពូជធ្វើតេស្តទៅអោយត្រូវពន្លឺថ្ងៃផ្ទាល់

-មិនត្រូវយកទឹកម៉ាស៊ីនមកប្រើក្នុងការបណ្តុះ សាក

-ផ្តល់ទឹកបន្ថែមដោយប្រុងប្រយ័ត្ន ប្រសិនបើពិនិត្យឃើញថាសំណើមក្នុងប្រអប់ស្ងួត

***ការសាកល្បងដំណុះគ្រាប់ជាក់លាក់* (Specific Emergence test )**

គឺជាការសាកល្បងគ្រាប់ពូជជាមួយនឹង ដីឬបរិយាកាសនៅតំបន់ឬកន្លែងដែលត្រូវដាំ ការធ្វើយ៉ាងនេះវា មានលក្ខណៈប្រាកដប្រជាថាប្រភេទពូជដែលបានសាកនេះវាអាចឬ មិនអាចដាំបាននៅលើដីដែលយើងចង់ដាំព្រោះលទ្ធផលដំណុះបានមកពីការសាកល្បង វាអាចបញ្ជាក់ប្រាប់យើងយ៉ាងជាក់លាក់ ។

វិធីអនុវត្តមានលក្ខណៈដូចខាងក្រោមៈ

- រៀបចំប្រអប់បណ្តុះ ទំហំ- ១៥ សម X ២៥ សម
- ដាក់ដីចំការដែលត្រូវដាំ កំរាស់ ៥-៦សមពីបាតប្រអប់
- បាញ់ទឹកដោយប្រើប្រដាប់បាញ់ទឹកតូច ផ្សើមក្នុងកំរិត ៦0-៧0%
- ចាប់យកដោយចៃដន្យ នូវគ្រាប់ពូជដែលចង់បណ្តុះ ១00គ្រាប់

- ឆូតជាចង្អូរជំរៅ ០,៥សម អោយបាន ១០ជួរក្នុង១ប្រអប់ហើយដាក់គ្រាប់ពូជចូល១០០គ្រាប់
- លប់គ្រាប់ពូជដោយប្រើដៃនិងសង្កត់វាធ្វើយាងណាអោយគ្រាប់ពូជប៉ះជាប់និងដី
- សរសេរផ្លាក កត់ត្រាពី ឈ្មោះពូជ ប្រភពពូជ លេខឡូ ថ្ងៃ ខែ ឆ្នាំធ្វើតេស្ត បិទពីលើគំរបប្រអប់
- សរសេរឈ្មោះអ្នកធ្វើពិសោធន៍ ហើយយកទៅទុកនៅកន្លែងដែលមានសុវត្ថិភាព
- ចាប់ផ្តើមរាប់ដំណុះគ្រាប់នៅថ្ងៃ១៥បន្ទាប់ ចំពោះស្មៅ និង ១០ថ្ងៃសម្រាប់ពពួកលេហ្គីម

*ង/កំរិតកំណត់ដំណុះគ្រាប់ពូជ*

គ្រាប់ពូជបន្ទាប់ពីធ្វើការបណ្តុះសាក យើងបានដឹងពីលទ្ធផលរបស់វា នោះយើងអាចសំរេចចិត្តក្នុងការប្រើប្រាស់បានល្អ។ជាទូទៅតាមការស្រាវជ្រាវរបស់អ្នកបច្ចេកទេសគេកំណត់ទៅលើកំរិតដែលអាចប្រើបាន និងមិនអាច ប្រើបានអាស្រ័យទៅតាម ប្រភេទពូជ និង អត្រាដំណុះគ្រាប់របស់វា ។

*ពពួកស្មៅ*(Grass )

- កំរិតដំណុះច្រើនជាង ២០%យើងប្រើប្រាស់វាបានល្អ
-គ្រាប់ពូជស្ថិតក្នុងដំណេកគ្រាប់ហើយមានដំណុះតិចជាង២០%រក្សាទុក៣-៦ខែហើយធ្វើតេស្ត បើដុះល្អអាចដាំវាបាន។
- ដំណុះគ្រាប់តិចជាង ២០%គុណភាពគ្រាប់អន់មិនត្រូវប្រើប្រាស់វាឡើយ ប៉ុន្តែបើចង់ប្រើប្រាស់វាទាល់តែអ្នក បង្កើនកំរិតនៃការព្រោះ ឬរកពូជថ្មីមកជំនួស។

*ពពួកលេហ្គីម* (Legume )

-គ្រាប់មានគុណភាពល្អ កំរិតដំណុះច្រើនជាង ៤០%ការដាំមានការដុះលូតលាស់ល្អ
- កំរិតដំណុះគ្រាប់ច្រើនជាង ៤០% តែវាមានសំបកគ្រាប់ក្រាស់ រឹង ត្រូវដាស់ដំណេកគ្រាប់
- ដំណុះគ្រាប់តិចជាង ៤០% ពិនិត្យឃើញគុណភាពគ្រាប់អន់មិនអាចប្រើបាន ។ បើចង់ប្រើប្រាស់ ពូជនេះ នោះអ្នកត្រូវបង្កើនបរិមាណ កំរិតព្រោះ ឬ រកពូជថ្មីជំនួស។




សាកល្បងដំណុះគ្រាប់ពូជ

### ៥.៣- ប្រតិទិនដាំដុះដំណាំចំណីសត្វ

ជាទូទៅពេលវេលាក្នុងការដាំដុះចំណីសត្វភាគច្រើនចាប់ផ្ដើមនៅរដូវវស្សា តែតំបន់ខ្លះមានដំណើរការចាប់ពី ចុងរដូវប្រាំង ក្នុងអំឡុងខែ កុម្ភៈ ទៅ ចំពោះតំបន់ដែលមានទឹកស្រោចស្រពគ្រប់គ្រាន់។

| ល.រ | សកម្មភាពអនុវត្ត | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | *ពូកស្ទៅដាំដោយគ្រាប់* | | | | | | | | | | | | |
| | រៀបចំដី | | | | | | | | | | | | |
| | ដំណើរការដាំ | | | | | | | | | | | | |
| | ថែទាំ និង ប្រមូលផល | | | | | | | | | | | | |
| ២ | *ពពួកស្មៅដាំដោយដើម* | | | | | | | | | | | | |
| | រៀបចំដី | | | | | | | | | | | | |
| | ដំណើរការដាំ | | | | | | | | | | | | |
| | ថែទាំ និង ប្រមូលផល | | | | | | | | | | | | |
| ៣ | *ពួកលេហ្គីមដាំដោយគ្រប់* | | | | | | | | | | | | |
| | រៀបចំដី | | | | | | | | | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដំណើរការដាំ | | | | | | | | | | | | |
| | ថែទាំ និង ប្រមូលផល | | | | | | | | | | | | |
| ៤ | *ពូកលេហ្គីមដើមឈើ ដាំដោយគ្រាប់* | | | | | | | | | | | | |
| | បណ្តុះគ្រាប់ | | | | | | | | | | | | |
| | ដំណើរការដាំ | | | | | | | | | | | | |
| | ថែទាំ ប្រមូលផល | | | | | | | | | | | | |
| ៥ | *ពូកលេហ្គីមដើមឈើ ដាំដោយគ្រាប់* | | | | | | | | | | | | |
| | បណ្តុះកូន | | | | | | | | | | | | |
| | ដំណើរការដាំ | | | | | | | | | | | | |
| | ថែទាំ និងប្រមូលផល | | | | | | | | | | | | |

.ពេលវេលាដំណើរការសកម្មភាពនៃការដាំដុះនេះមានការប្រែប្រួល *អាស្រ័យទៅនឹង របបទឹកភ្លៀង ទីកន្លែងដាំដុះ និងប្រភពទឹកស្រោចស្រព ។*

**៥.៤-បច្ចេកទេសក្នុងការដាំដំណាំចំណីសត្វ**

ការដាំដំណាំចំណីសត្វ ជាសំខាន់គេអនុវត្តតាម ៤ របៀប ដែលរបៀបនីមួយៗប្រែប្រួលទៅតាមប្រភេទពូជ និងទៅតាមលក្ខណៈជីវសាស្ត្ររបស់វា វិធីទាំងនោះមានៈ វិធីដាំដោយគ្រាប់ផ្ទាល់ ដាំដោយបំបែកគល់ ដាំដោយកូន បណ្តុះ វិធីដាំដោយដើម ឬមែកបណ្តុះ ។

***ក-វិធីដាំដោយគ្រាប់ផ្ទាល់***

វិធីនេះភាគច្រើនគេអនុវត្ត ទៅលើពូកស្មៅ និង លេហ្គីមមួយចំនួនដែលមានគ្រាប់តូចៗ និងមានសំបកគ្រាប់ ស្តើងៗ ដែលមានលក្ខណៈងាយស្រួលដុះ និងមានលទ្ធភាពបឺតសំណើមពីដី ដើម្បីដុះពន្លកបានល្អ។

ពពួកស្មៅស្ទើរតែគ្រប់ប្រភេទពូជ គេអាចដាំវាបានដោយប្រើគ្រាប់ផ្ទាល់ លើកលែងតែ ក្រុមនេពារ ដូចជា យីងក្រាស ស្មៅដំរី ដែលយើងដាំវាដោយប្រើដើម។ ក្រៅពី ស្មៅមានពពួកលេហ្គីម ដូចជា ស្តាយឡូ ឱសមិនធុស និងពពួកលេហ្គីមដើមវល្លិមួយចំនួនទៀតដែលអាចដាំវាដោយគ្រាប់ដូចជាពពួកស្មៅដែរ(មើលតារាងទំព័រទី២២) ។

បច្ចេកទេសដាំដោយប្រើគ្រាប់មានៈ

-រៀបចំដីអោយហ្មត់ល្អ រាបស្មើ និងធ្វើការសំអាតស្មៅចង្រៃ ចេញអោយស្អាតមុនពេលដាំ

-ឆ្វួតដីដោយប្រើចប ធ្វើជាចង្អូរ ជំរៅ ៣ ស.ម - ៣,៥ស.ម អោយត្រង់ល្អ សម្រាប់ដាក់គ្រាប់ដាំ

-ដាក់គ្រាប់ដាំតាមចង្អូរឆ្វួតរួច កប់ដីក្នុងជំរៅ១,៥ស.ម - ២ ស.ម ហើយបង្ហាប់អោយគ្រាប់ប៉ះនិងដី

-ករណើដាំជាជួរ ទុកចន្លោះពីជួរមួយទៅជួរមួយ ៣៥-៤០ស.ម ធ្វើយ៉ាងនេះងាយគ្រប់គ្រងសំអាតស្មៅ

-ការដាំអាចរោយដោយដៃ ឬ ប្រើកំប៉ុងចោះរន្ធ ដាក់គ្រាប់ចូលហើយគោះទំលាក់គ្រាប់ តាមចង្អូរជួរ

- បរិមាណគ្រាប់ដែលដែលប្រើ ៤-៥គក្រ/ហិតាចំពោះគ្រាប់ដែលមានដំណុះពី ២០-៣០%

-បើដាំជាលក្ខណៈសាប យើងចាំបាច់គោរពតាមបទដ្ឋានបច្ចេកទេសក្នុងការប្រើគ្រាប់គឺ ៤-៥គក្រក្នុង មួយហិកតា



ដាំគ្រាប់ពូជដោយប្រើកំប៉ុងគោះ



ដាំគ្រាប់ពូជ រោយដោយដៃ

### *ខ-ការដាំដោយប្រើដើមបំបែក*

ការបំបែកដើមដំណាំចំណីសត្វដើម្បីដាំភាគច្រើនគេអនុវត្តបានតែនៅលើ ពពួកស្មៅចំណីសត្វ ដែលមាន កំពស់ដើម ទាប និងកំពស់ ដើមមធ្យម ។ ចំពោះពួកស្មៅមានកំពស់ដើមខ្ពស់ ពួកលេហ្គឹម និងលេហ្គឹដើមឈើ ប្រភេទ ខ្លះយើងអាចបំបែកវា ដាំបានតែវាពុំសូវទទួលលទ្ធផលល្អ ហើយជួនពេលខ្លះដុះលូតលាស់ តែមានសភាពយឺតយ៉ាវពិបាកក្នុងការថែទាំអោយលូតលាស់ល្អនាំអោយមានការចំណាយពេលវេលាយូរ(មើលតារាងកំណត់សំគាល់ការប្រើប្រាស់ពូជខាងលើ) ។

ការបំបែកស្មៅចំណីសត្វគេអនុវត្តនូវ វិធីសាស្ត្រដូចខាងក្រោមៈ

-ចាប់ផ្តើមដំណើរការអនុវត្តសកម្មភាពបំបែកស្មៅចំណីសត្វនៅពេលដែលមានភ្លៀងធ្លាក់ជោគជាំល្អ

-គេអាចបំបែក វានូវរដូវមិនមានភ្លៀងគ្រប់គ្រាន់ក៏បានប្រសិនបើមានប្រភពទឹកស្រោចស្រពត្រឹមត្រូវ

-រៀបចំដីនៅកន្លែងដាំដែលត្រូវដាំអោយហ្មត់ល្អ ហើយរើសសំអាតស្មៅចង្រៃចេញអោយស្អាត

-បំបែកកូនកូនស្មៅមួយចំនួនចេញពីគុម្ពរបស់វា ពេលវាមានអាយុចាប់ពី ៣០-៦០ ថ្ងៃបន្ទាប់ពីដាំ

-ជ្រើសរើសកូនស្មៅដែលមានដើមថ្លុះល្អមានកំពស់ទាបល្មមនៅក្នុងគុម្ព (មិនខ្ពស់ពេកនៅក្នុងគុម្ព)

-កាត់ស្លឹកក្នុងកំរិត ២/៣ចេញ ដើម្បីអោយវាមានសភាពរឹងមាំនៅពេលដាំ និងលូតលាស់បានល្អ

-ចំពោះការដឹកជញ្ជូនទៅដាំនៅដំបន់ឆ្ងាយត្រូវរុំកូនពូជស្មៅដែលរំលែកដោយក្រដាស់ផើ្សមទឹក ហើយ ច្រកចូស្បោងផ្លាស់ស្ទិកបិទអោយជិត ។

-សរសេរផ្លាក កត់ត្រាពី ឈ្មោះពូជ ទីកន្លែងផ្តល់ពូជ អ្នកផ្តស់ពូជ ទីកន្លែងផ្ញើទៅ មុនពេលដឹកជញ្ជូន ឬផ្ញើរទៅកន្លែងដាំផ្សេងទៀត ។

-ការរៀបចំវិចខ្ចប់បែបនេះមិនត្រូវទុកអោយលើពីរយៈពេល៥ថ្ងៃ

-ការដាំ ត្រូវរៀបចំជាជួរ ដោយទុកចន្លោះជួរ ៤០ស.ម ចន្លោះគុម្ព ១,៥ - ២ស.ម

-ពេលដាំត្រូវកប់គល់ ក្នុងជំរៅ ៣ - ៤ស.មទៅក្នុងដីហើយសង្កត់ដីអោយណែនល្អជៀសវាងកាដួល ។





របៀបវិចខ្ចប់កូនពូជ　　　　　　　　　　របៀបដាំដោយប្រើកូនពូជរំលែក

***គ-ការដាំណាំចំណីសត្វដោយកូនបណ្តុះ***

វិធីដាំដំណាំចំណីសត្វដោយកូនបណ្តុះភាគច្រើនគេអនុវត្តន៍ទៅលើពូកលេហ៊ីមដើមឈើ ដែលគ្រាប់វាមានសំបកក្រាស់ពិបាកក្នុងការដុះប្រសិនបើយើងដាំផ្ទាល់ដោយមិនបណ្តុះគ្រាប់វាជាមុន ។ វិធីបណ្តុះគេអាចអនុវត្តបានតាមពីររបៀប គឺការបណ្តុះគ្រាប់ដោយប្រើថង់បណ្តុះ និងការបណ្តុះដោយថ្នាល បណ្តុះ ។

ចំពោះដីសម្រាប់បណ្តុះត្រូវរៀបចំជាល្បាយមាន ៦០% ដី១៥% កំប៉ុស្ត១៥% អង្កាមពុកៗឬអាចម៍រណានិង១០%ជាលាមកគោគ្រៀមច្របល់ចូលគ្នាអោយសព្វល្អទើបដំណើរការដាក់គ្រាប់បណ្តុះ ។

សម្រាប់កាបណ្តុះក្នុងថង់ ដាក់គ្រាប់ ១-២គ្រាប់/១ថង់ បើបណ្តុះដោយថ្នាលគោរពតាមបទដ្ឋាន ៣០០ទៅ ៤០០ គ្រាប់ក្នុងផ្ទៃដី១ម៉ែត្រការ៉េ ។

គេអាចដាំកូនដំណាំចំណីសត្វ នៅជុំវិញផ្ទះ ជុំវិញរបងចំការដំណាំ បើដាំជាលក្ខណៈចំរុះត្រូវរៀបវានៅផ្នែក ខាងបង្អស់នៃចំការ ព្រោះពូជដំណាំចំណីសត្វដែលគេនិយមបណ្តុះកូនដើម្បីដាំ ភាគច្រើនមានដើមធំបើដាំវានៅ កណ្តាល វានឹងផ្តល់ផលប៉ះពាល់ដល់ដំណាំដែលមានដើមទាប ។

បច្ចេកទេសក្នុងការដាំដំណាំចំណីសត្វដោយកូនបណ្តុះរួមមាន:

-កូនបណ្តុះចាប់ផ្តើមយកទៅដាំនៅពេលវាមានអាយុចាប់ពី ៤៥-៦០ថ្ងៃបន្ទាប់ពីបណ្តុះ

-ជាការល្អចំពោះការដកកូនដែលបានសាបដោយថ្នាលដកវានៅពេលមានភ្លៀងធ្លាក់ភ្លាមបើគ្មាន ភ្លៀងគួរស្រោចទឹកវាអោយបានជោគ ហើយទុកវារយៈពេល២៤ម៉ោងទើបដកជាការល្អព្រោះដីធូងាយដក ។

-កាត់ស្លឹក និងចុងត្រួយចេញដោយប្រើកូនកាំបិតមុត ហើយជៀសវាងការកាច់ដោយដៃ

-ជុំរះសំអាតដី នៅកន្លែងដែលត្រូវដាំ ជីករណ្តៅមានអង្កត់ផ្ចិត១០-១៥ស.ម ជុំរៅ២០-៣០ ស.ម

-បាដីផ្នែកខាងលើកំរាស់ប្រហែល៥ស.មទុកមួយកន្លែងសម្រាប់កប់គល់កូនដំណាំព្រោះវាជាដីជីជាតិ

-ដាក់ជីកំប៉ុស្ត ឬ ជីលាមកសត្វចូលទៅក្នុងរណ្តៅប្រមាណ១/៣នៃដីដែលត្រូវកប់គល់ដំណា ំហើយច្របល់វាអោយសព្វល្អ ជាមួយដីដែលបានបាទុក។

- រៀបចំរណ្តៅបានល្អ ដាក់កូនដំណាំចំណីសត្វចូលទៅក្នុងរណ្តៅ លៃយ៉ាងណាកុំអោយបទចុងឬស បើជាកូនបណ្តុះដោយថង់ត្រូវកាត់យកថង់មណ្តុះចេញមុនពេលកប់គល់វា ការកប់គល់ត្រូវជាន់បង្ហាប់អោយណែន។

-គ្របគល់ដំណាំដោយប្រើចំបើងឬកំទេចកំទីសំរាមអោយបានជិតល្អ ដើម្បីរក្សាសំណើមដី។

-ស្រោចទឹកអោយបានជោគ១00% រយះពេល ៤-៥ថ្ងៃបន្ទាប់ពីថ្ងៃដាំ។

ព្យាយាមសំអាតស្មៅចង្រៃជុំវិញគល់ដំណាំអោយបានស្អាត ពេលដំណាំនៅតូច ឬ ការដុះលូតលាស់មិនទាន់បាន ល្អ រយៈពេល៧-១០ថ្ងៃបន្ទាប់ពីដាំ កូនដំណាំចំណីសត្វ វានឹងចាប់ផ្តើមដុះពន្លកស្លឹកនៅតាមភ្នែករបស់វា។ ៤៥-៦៥ថ្ងៃបន្ទាប់ពីដុះស្លឹក យើងអាចចាប់ផ្តើមប្រមូលផលវាក្នុងកំរិតតិចតួចបាន។

*ឃ-វិធីដាំដោយដើម ឬ មែកបណ្តុះ*

ដំណាំចំណីសត្វច្រើនប្រភេទ មានលទ្ធភាពក្នុងការដុះលូតលាស់ជាដើមថ្មីបាន ដោយសារមែក ឬ ដើមរបស់ វាតាមរយៈការដាំផ្ទាល់និងតាមការបណ្តុះមែក។ ប្រភេទដំណាំចំណីសត្វទាំងនោះរួមមានក្រុមស្មៅនេពារ (Napier) ដូចជា ស្មៅដឺរី ស្មៅឃីងក្រាស ពួកលេហ្គឹមដើមឈើមួយចំនួនមាន គ្លីរីស៊ីដ្យា មន ទ្រើ ចាន់ត្រា រួមជាមួយប្រភេទ មួយចំនួនទៀត។ របៀបដាំដំណាំចំណីសត្វប្រភេទនេះ ត្រូវការរៀបចំជាលក្ខណៈបច្ចេកទេសផ្សេងៗ គ្នាដូចជា:

*ពួកស្មៅនេពារ*

-រៀបចំដីអោយបានស្អាតហើយ ជីករណ្តៅទំហំ១៥ ស.ម - ២០ស.ម ជំរៅ ២០-២៥ ស.ម

-រៀបចំ ចន្លោះជួរ ៤0-៥0ស.ម ចន្លោះគុម្ព ៤0 ស.ម

-លាយជីលាមកសត្វ ឬជីកំប៉ុស្ត ក្នុងកំរិត ១/៣ជាមួយដី ដោយច្របល់អោយបានសព្វល្អក្នុងរណ្តៅ

-ជ្រើសរើសដើមស្មៅដែលមានលក្ខណៈរឹងមាំល្អ ហើយជាដើមដែលនៅខ្ចីល្មមដើម្បីបណ្តុះ

-ពិនិត្យចំណុចដំណុះ(ភ្នែក)របស់វាមិនខ្វាក់ ឬមិនរបកទើបជាការល្អហើយពេលដាំត្រូវដាក់ភ្នែកវា អោយនៅផ្នែកខាងលើ ឬ ផ្នែកចំហៀង តែត្រូវជៀសវាងដាក់នៅផ្នែកខាងក្រោម។

-កាត់ដើមវាជាកង់ៗ ប្រវែងពី៣0-៣៥ ស.ម ហើយលៃយ៉ាងណាអោយជាប់៣ថ្នាំង/១កង់

-ដាក់ដើមដាំ១-២កង់/១រណ្តៅ ដោយរៀបក្នុងទំរេតមុំ ៤៥ ដឺគ្រេ និងលប់ដីសង្កត់អោយណែនល្អ

-គ្របរណ្តៅដែលដាំរួចដោយគល់ជញ្ជ្រាំង ចំបើង ឬសំរាម ហើយស្រោចទឹកអោយជោគ៤-៥ថ្ងៃ

ការដាំបែបនេះក្នុងករណីថែទាំបានល្អវានឹងចាប់ផ្តើមដុះពន្លកនៅពេលវាមានអាយុ ៧-១០ថ្ងៃ បន្ទាប់ហើយ ផ្តល់ផលនៅពេលវាមានអាយុ ៣0-៦0ថ្ងៃបន្ទាប់ពីដាំ យើងអាចកាត់វាផ្តល់អោយសត្វបានជាបន្តបន្ទាប់។

*ពូកលេហ្គីមដើមឈើ*

ចំពោះពួកមន ទ្រីចាន់ត្រា គ្លីរីស៊ីដ្យា ដែលជាពួកដើមឈើលេហ្គីមគេអាចដាំវាបានដូចគ្នាទៅ នឹងស្នោនេពារ ដែរ តែការដុះលូតលាស់របស់វា មិនសូវបានល្អ ហេតុនេះ ដើម្បីអោយវាមានដំណើរការល្អចាំបាច់ត្រូវការផ្សាំមែក របស់វាអោយដុះពន្លកជាមុនសិន ទើបដាំ របៀបនៃការដាំវារួមមាន:

-កាត់មែកពូជ ណាដែលនៅខ្ចីល្មម (សំគាល់សំបកវាមានពណ៌បៃតងចាស់)ជាកង់ៗប្រវែង ២០-២៥ ស.ម ដោយធ្វើយ៉ាងណាកុំអោយរបកសំបកក្នុងពេលកាត់ ឬ ពេលដឹកជញ្ជូន។

-លាយដីជាមួយជីកំប៉ុស្ត ឬជីលាមកសត្វកំរិត១/៣ ហើយច្របល់វាចូលគ្នាអោយសព្វល្អច្រកចូលស្បោងបណ្តុះ។

-ដាក់ដើមពូជបណ្តុះក្នុងស្បោង រយៈពេល ១០-១៥ថ្ងៃ បន្ទាប់មកយកវាទៅដាំ

-មុនពេលដាក់កូនដំណាំចំណីសត្វដាំត្រូវកាត់យកស្បោងបណ្តុះចេញ ដើម្បីអោយឬសវាលូតបានល្អ និងធ្វើការបង្ហាប់ដីអោយបានណែនល្អ។

-គ្របគល់កូនដំណាំដោយចំបើង ប ឬកំទេចសំរាម ហើយស្រោចទឹកវាអោយជោគល្អរយៈពេល ៤-៥ថ្ងៃបន្ទាប់ពីដាំ។

-ការដាំរៀបចំ ចន្លោះជួរ ២,៥-៣ម ចន្លោះដើម ២-២,៥ម

ក្រោយពេលដាំរយៈពេល ៤៥-៦០ថ្ងៃ ដំណាំ និង ដុះស្លឹកពេញលេញ នោះយើងអាច ចាប់ផ្តើមប្រមូលផល វាក្នុងកំរិត៣0-៤0% ហើយនិងអាចប្រមូលផលជាលើកបន្តបន្ទាប់ទៀត នៅពេលស្លឹកវាដុះលូតលាស់ពេញលេញ។

ការប្រមូលលផលត្រូវមានការប្រុងប្រយ័ត្នជៀសវាង ការកាច់ដោយដៃ ការកាត់ដោយកាំបិត មិនសូវមុត ឬការទាញអោយរហែកសំបក ដែលជាប្រការនាំអោយដំណាំចំណីសត្វមានការដុះលូតលាស់យឺត ឬអាចមានការខូចខាតទាំងស្រុងក៏មាន។



ចំណុចដំណុះ របស់ស្នោពួក នេពារ



របៀបបណ្តុះមែកពូជ

### ង/ការរៀបចំប្លង់ដាំដំណាំចំណីសត្វ

ដំណាំចំណីសត្វគេអាច រៀបចំដាំបានច្រើនរបៀប វាអាស្រ័យទៅនឹង ជម្រើសឬចំណង់ចំណូលចិត្តរបស់អ្នកដាំ តែជាលក្ខណៈបច្ចេកទេស រួមជាមួយនិងបទពិសោធន៍របស់កសិករ ការដាំត្រូវបានរៀបចំឡើងតាមបីរបៀបគឺៈ

-ការដាំដំណាំចំណីសត្វតែមួយប្រភេទពូជ

-ការដាំជាប្លង់លក្ខណៈចំរុះពូជ

-ការដាំជាលក្ខណៈដូរឆ្លាស់ពូជ

ចំពោះបច្ចេកទេសដាំ មានលក្ខណៈប្រហាក់ប្រហែលគ្នា តែវាមានការខុសគ្នា ទៅលើ បច្ចេកទេសរៀបចំ បែង ចែកប្លង់ដាំដុះ វិធីនៃការប្រើប្រាស់ពូជ និងពេលខ្លះត្រូវការមានរបៀបគ្រប់គ្រង ចាត់ចែងខុសៗគ្នាផងដែរ។

#### ១ ការដាំដំណាំចំណីសត្វតែមួយប្រភេទពូជ

កសិករ ឬអ្នកដាំដំណាំចំណីសត្វអាចជ្រើសយកនូវវិធីដាំដំណាំចំណីសត្វតែមួយមុខគត់នៅក្នុងចំការចំណីសត្វមួយប្លង់ ដោយគេអាចដាំ ជាលក្ខណៈចំការស្មៅ ចំការពួកលេហ្គីម ឬដាំលេហ្គីមដើមឈើ។ ការបង្កើតអោយមាន ចំការដំណាំបែបនេះភាគច្រើនជាការដាំដែលបំពេញអោយលក្ខណៈដូចខាងក្រោមៈ

-ដាំជម្រើសតាមពូជដែលគេពេញចិត្ត ដូចជា ដុះលូតលាស់លឿន គុណភាពល្អ បរិមាណផលច្រើន

-ដាំបំពេញតាមតំរូវការប្រើប្រាស់ ឬតំរូវទៅតាមប្រភេទសត្វដែលគេចិញ្ចឹម ដូចជា អ្នកចិញ្ចឹមពពែ គេត្រូវការដាំពួកលេហ្គីមដើមឈើ ប្រភេទ គ្លីរីស៊ីដ្យាច្រើនសរាប់យកស្លឹកផ្តល់ជាចំណីវា។

-ដាំតំរូវទៅតាមស្ថានភាពដីជាតិដី អាកាសធាតុ តំបន់ដែលមានលក្ខណៈអំណោយផលអោយ ឧទាហរណ៍ នៅតំបន់ជួមាត់ទន្លេ ដោយសារទឹកជំនន់នៅរដូវវស្សា កសិករភាគច្រើននិយមដាំនូវពួកស្មៅ នេពា ព្រោះវាមានដើមខ្ពស់ ហើយវាធានាបានទៅនឹងការលិចទឹកល្អជាងប្រភេទស្មៅដទៃទៀត។

នៅមានលក្ខណៈផ្សេងៗទៀតជាច្រើនដែលតំរូវអោយកសិករជ្រើសរើសយកនូវវិធីដាំដំណាំចំណីសត្វតែ មួយមុខ ឬមួយប្រភេទពូជ។

#### ការដាំជាលក្ខណៈចំរុះពូជ

ការដាំដំណាំចំណីសត្វជាលក្ខណៈចំរុះពូជ វាជាវិធីដាំដុះមួយប្រភេទដែលអាចចាត់ទុកថាសមស្រមទៅ នឹង លក្ខណៈបច្ចេកទេសព្រោះវាបានបំពេញតំរូវការប្រភេទចំណីសម្រាប់សត្វ និងបានរៀបចំដំណាំចំណីសត្វ ត្រឹមត្រូវ ទៅ តាមលក្ខណៈជីវសាស្ត្ររបស់វា ការងាររៀបចំគឺៈ

-រៀបចំប្លង់ដីមួយអោយសមស្រប និងការដាំដុះដំណាំចំណីសត្វ

-ពិនិត្យស្ថានភាពដី និងធ្វើការបែងចែកវាជាកូនប្លង់តូចៗ នៅក្នុងប្លង់ធំ

-រៀបចំដីទៅតាមស្ថានភាព និងតំរូវការរបស់ពូជដើម្បីអោយដំណាំនីមួយៗងាយស្រួលក្នុងការដុះ លូតលាស់បានល្អ។

-ដាំប្រភេទដំណាំចំណីសត្វទៅតាមប្លង់ដែលបានរៀបចំហើយនិងទៅតាមប្រភេទដំណាំដែលយើងចង់ដាំ។

ការរៀបចំប្លង់ដាំតាមលក្ខណៈចំរុះ បែបនេះវាមានផលលំបាកដោយ ត្រូវការផ្ទៃដីធំទើបយើងអាចរៀបចំ

បានងាយស្រួល និងម្យាងទៀតអ្នកដាំត្រូវយល់ដឹងអោយបានច្បាស់ពី ប្រភេទដំណាំនិមួយៗ ជាពិសេសទំហំនៃការលូតលាស់របស់វា ដើម្បីអោយការរៀបចំដំណើរការដាំបានសមស្រប ។

***ការដាំជាលក្ខណៈជួរឆ្លាស់ពូជ***

ការដាំដំណាំចំណីសត្វជាលក្ខណៈជួរឆ្លាស់វាជាបច្ចេកទេសថ្មីមួយដែលអាចជួយអោយកសិករ ឬអ្នកដាំទូទៅ អនុវត្តបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដាំដុះដំណាំចំណីសត្វ ។

ការរៀបចំការដាំបែបនេះវាមានសារៈសំខាន់ ច្រើនដូចជា:

-មានប្រភេទដំណាំចំណីសត្វច្រើនប្រភេទនៅក្នុងចំការតែមួយហើយអាចតំរូវបានតាមតំរូវការសារធាតុចំណីដែលសត្វត្រូវការ ។

-ដោយវាមានលក្ខណៈជាជួរត្រង់ និងមានចន្លោះជួរច្បាស់លាស់វាសំរួលដល់ការងារសំអាតស្មៅ ចង្រៃ ហើយនិងមានភាពងាយស្រួលក្នុងការថែរក្សាដំណាំ ។

-ជួយអោយអ្នកដាំងាយក្នុងការធ្វើប្លង់កំណត់សំគាល់ពូជបានត្រឹមត្រូវ ដោយគ្រាន់តែបង់លេខ សំគាល់នៅលើក្រដាស់ប្លង់ នៅពេលចាប់ផ្តើមដំណើរការដាំ ។

-ការឆ្លាស់ជួររវាងស្មៅ និង លេហ្គីមអាចជួយដល់ការងារថែរក្សាដីជាតិដីបានល្អជាងប្លង់ ដាំដំណាំ ចំណីសត្វតែមួយប្រភេទ និងប្លង់ដាំជាលក្ខណៈចំរុះ ព្រោះពួកលេហ្គីមភាគច្រើនវាជួយបង្កើនជីជាតិដី ។

ការដាំដំណាំចំណីសត្វតាមរបៀបជាជួរឆ្លាស់ពូជដំណើរការទៅបានលុះត្រាតែមានការរៀបចំ ការងារមួយ ចំនួនដូចខាងក្រោម:

-រៀបចំប្រភេទពូជដែលមានអាយុកាលដុះលូតលាស់ប្រហាក់ប្រហែលគ្នា

-រៀបចំពូជដែលមានកំរិតនៃការលូតលាស់កំពស់ និងកំរិតការបែកគុម្ពប្រហាក់ប្រហែលគ្នា

-រៀបចំដាំប្រភេទដំណាំចំណីសត្វដែលមានដើមធំ និងខ្ពស់នៅផ្នែកខាងៗនៃចំការ

-រៀបអោយមានការឆ្លាស់ជួររវាង ប្រភេទស្មៅជាមួយពួកលេហ្គីម ជៀសវាងឆ្លាស់ជួររវាងស្មៅនិងស្មៅ ប្រសិនបើអាចធ្វើទៅបាន ។

***រូបភាពនៃការរៀបចំប្លង់ដាំដំណាំចំណីសត្វ***





ដាំតែមួយប្រភេទពូជ ដាំជាប្លង់ចំរុះពូជ ដាំ ជាជួរឆ្លាស់ពូជ

*ច/តារាងសង្ខេបកំរិតដាំដុះដំណាំចំណីសត្វ*

| *ប្រភេទពូជ* | *បរិមាណពូជប្រើជាធ្យូម (ហិត)* | *ចន្លោះជួរ (សម)* | *ចន្លោះគុម្ព (សម)* | *ផ្សេងៗ* |
|---|---|---|---|---|
| *ស្មៅដាំដោយគ្រាប់* | *៤-៥គក្រ* | *៤០* | *០* | *កំរិតដំណុះ២០%* |
| *ស្មៅដាំដោយគល់* | *១៧០០០គល់* | *៤០* | *១០-១៥* | *កំរិតដំណុះ១០០%* |
| *ពូកលេហ្គីមដាំគ្រាប់* | *៤-៥គក្រ* | *៤០* | *០* | *កំរិតដំណុះ៤០%* |
| *ពូកស្មៅនេពារ* | *១២៥០០កំណាត់* | *៤០-៥០* | *៤០* | *កំរិតដំណុះ១០០%* |
| *លេហ្គីមដើមឈើ* | *២០០០ ដើម* | *២៥០-៣០០* | *២០០-២៥០* | *កំរិតដំណុះ១០០%* |

### ៥.៥- សំភារៈប្រើប្រាស់ក្នុងការដាំដុះដំណាំចំណីសត្វ

*ក្នុងការដាំដំណាំចំណីសត្វ តាមប្លង់ដីតូចៗជាលក្ខណៈគ្រួសារ ការត្រៀមបំរុងសំភារៈ សម្រាប់ធ្វើការដាំដុះមិន មានអ្វីជាសំខាន់ គឺប្រើប្រាស់នូវសំភារៈណាដែលកសិករមាននៅក្នុងតំបន់របស់គាត់ សំភារៈទាំនោះមានៈ*

*សំភារៈសម្រាប់ធ្វើរបងការពារៈ*

- *បង្គោលរបង អាចប្រើកូនឈើ គល់ឬស្សី ធាងដូង ឬ ធាងត្នោត*
- *របាសម្រាប់បាំងពទ្ធ័ជុំវិញចំការដំណាំ អាចប្រើដើម ឬសស្សី សំរះបន្ទា ឬអ្វីៗដែលអាចរកបាន*
- *សំភារៈសម្រាប់ចង ឬវាយភ្ជាប់ មាន ដែកគោល ឬខ្សែចំណងរបា ពោះធាងត្នោត ឬ វល្លិ*

*សំភារៈសម្រាប់ដាំ*

- *ខ្សែសិន ឬខ្សែសម្រាប់ជាគោលក្នុងការឆូតជួរ នៅពេលដំណើរការដាំ ដើម្បីអោយជួរត្រង់ល្អ*
- *ចបជុំរៈប្រើសម្រាប់ឆូតជាគន្លងជួរ សម្រាប់ដាក់គ្រូបពេលដាំ*
- *កំប៉ុងសម្រាប់គោះគ្រាប់ពូជនៅពេលដាំ ឬចានសម្រាប់ដាក់គ្រាប់រោយនៅពេលដាំ*
- *ចបជីក សម្រាប់ជីករណ្តៅ ក្នុងករណីដាំកូនដំណាំចំណីសត្វ*

*ការងារពូជដំណាំចំណីសត្វ*

- *បញ្ជីសម្រាប់កត់ត្រាគ្រាប់ពូជ( កត់ត្រាឈ្មោះគ្រាប់ពូជ ប្លង់ជួរគ្រាប់ពូជដែលបានដាំ)*
- *គ្រាប់ ឬកូនពូជដំណាំចំណីសត្វដែលត្រូវដំណើរការដាំ*
- *សំភារៈសម្រាប់ដាស់ដំណេកគ្រាប់ពូជ*
- *សំភារៈសម្រាប់ធ្វើការបណ្តុះកូនពូជ( មានកន្ត្រៃសម្រាប់កាត់ កូនកាំបិត ស្តុតរុំ ថង់បណ្តុះ កំប៉ុស្ត)*

*សំភារៈសម្រាប់បង្ហាញកសិករ ដើម្បីអោយកសិករសហការណ៍មានការយល់ដឹងមានការចូលរួមពីការរៀបចំ ឬងដាំ កត់សំគាល់បានពីឈ្មោះ ដំណាំតាមជួរដាំ និងយល់ដឹងគ្រួសៗអំពីបច្ចេកទេសដាំចាំបាច់ណាស់ យើងត្រូវធ្វើការពន្យល់កសិករជាក្រុម មុន ពេលដំណើរការដាំសំភារៈទាំងនោះមានៈ*

*- ក្រដាស់ផ្ទាំងធំ សម្រាប់ប្រើសម្រាប់ សរសេរបង្ហាញ ឬគូប្លង់ដាំបង្ហាញកសិករ*

*- ហ្វឺតសរសេរក្រដាស់ សម្រាប់សរសេរនៅពេលពន្យល់កសិករ*

*- ផ្ទាំងគំនូរ តួរស្រាប់ បញ្ជាក់ពីសកម្មភាព អនុវត្ត*

*ក្រៅពីនេះ ការត្រៀមកំលាំពលកម្មចូលរួមជាការងារសំខាន់ នៅក្នុងពេលដំណើរការដាំដំណាំចំណីសត្វ ហើយម៉្យាងទៀតអ្នកសំរបសំរួល ឬ អ្នកដឹកនាំអនុវត្ត ចាំបាច់ត្រូវតែមានការចូលរួមដោយមិនអាចខ្វះបាន ។*

៥.៦- ការថែទាំដំណាំចំណីសត្វក្រោយពេលដាំ

*ការថែទាំដំណាំចំណីសត្វវាជាចំណែកមួយនាំអោយការផ្សព្វផ្សាយ និងការអនុវត្តន៍សកម្មភាពពង្រីកផលិត កម្មដំណាំចំណីសត្វរបស់យើងទទួលបានជោគជ័យ ។ បើយើងទាំងអស់គ្នាគ្រាន់តែនាំគ្នាដាំ ដោយបោះបង់នូវសកម្ម ភាពថែទាំជាទូទៅវាបានធ្វើអោយកំរិតបរាជ័យរបស់យើង មានរហូតដល់ទៅ៩៥% ហើយវារិតតែមានផលលំបាក ធ្ងន់ធ្ងរថែមទៀតប្រសិនបើយើងអនុវត្តជាមួយកសិករ ។ ចំណុចសំខាន់ៗក្នុងការអនុវត្តលើការងារថែទាំដំណាំចំណីសត្វក្រោយពេលដាំរួមមានៈ*

*- ការពិនិត្យមើលជាប្រចាំ សំដៅធ្វើយ៉ាងណាកុំអោយមានកត្តាបំផ្លាញពីខាងក្រៅ ដូចជាគោ ក្របី ចូលស៊ីក្នុងចំការ ឬស្មៅចង្រៃដុះលប់ពេលដំណាំចំណីសត្វនៅតូច នាំអោយមានការខូចខាត ។*

*- ជំរះសំអាត( យកជើង) ពេលដំណាំចំណីសត្វនៅតូចដើម្បីអោយវាដុះលូតលាស់ល្អ*

*- យល់ដឹងអំពីភាពបាត់បង់ជីជាតិដី និងធ្វើការបន្ថែមជីទាន់ពេលវេលា*

*- យល់ដឹងពីវិធីកាត់ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដើម្បីអោយដំណាំមានលទ្ធភាពលូតលាស់ល្អ*

*- ព្យាយាមសន្សំជីធម្មជាតិដាក់ចំការដំណាំអោយបានទៀងរាល់ឆ្នាំ និងឧស្សាហ៍ក្នុងការពង្រីកការដាំ*

*- ថែទាំជាពិសេសនៅរដូវប្រាំង ទាំងការកាត់ ការផ្សាំពូជ ឬការផ្តល់ទឹក បើអាចធ្វើទៅបាន*

*- បង្កើនកំរិតការពារដំណាំចំណីសត្វកាន់តែខ្លាំង នូវរដូវប្រាំង ជៀសវាងការបោះបង់ចោល ដោយ យល់ឃើញថាវាផ្តល់ផលតិច ឬក៏ពុំសូវមានប្រយោជន៍សម្រាប់រដូវប្រាំង ។*

## ៦. ការគ្រប់គ្រងចំការដំណាំចំណីសត្វតាមគ្រួសារ

*ដំណើរការគ្រប់គ្រងដំណាំចំណីសត្វ មានគោលបំណងសំខាន់ ៤ គឺៈ*

*- គ្រប់គ្រងភាពស្ថិតស្ថេររបស់ដំណាំចំណីសត្វ ក្រោយពេលដាំ នោះមានអាយុកាលរស់នៅរបស់ ប្រភេទដំណាំ ការដុះលូតលាស់ នឹងកំណត់បានទូផលិតភាពរបស់ដំណាំចំណីសត្វ ។*

*- គ្រប់គ្រងទៅលើ បរិមាណគុណភាព និងភាពប្រែប្រួលរបស់ដំណាំចំណីសត្វ សំដៅធ្វើយ៉ាងណាបង្កើតនូវតុល្យភាពរវាងចំនួនសត្វនិងបរិមាណចំណីដើម្បីអោយកសិករមានលទ្ធភាពក្នុងការពង្រីកផលិតកម្មសត្វតាមគ្រួសារបាន ។*

*- គ្រប់គ្រងទៅលើការប្រើប្រាស់អស់លទ្ធភាពនូវអាហារូបត្ថម្ភសត្វក្នុងប្រពន្ធ័ដាំដំណាំចំណីសត្វតាម របៀបកាត់ផ្តល់អោយសត្វ ។*

- គ្រប់គ្រងទៅលើ ទំនាក់ទំនង រវាងដំណាំចំណីសត្វ ទៅនិងបរិស្ថាននៅតំបន់ដាំដុះ និងផលប៉ះពាល់ ផ្សេងៗ ដែលអាចកើតមាន និងការកែរលំអរទាន់ពេលវេលា ។

ដើម្បីសំរេចអោយបាន នូវគោលបំណងនៃការងារគ្រប់គ្រង ទាំងអស់ខាងលើ មធ្យោបាយសមស្រប និងមានលក្ខណៈបច្ចេកទេស ដែលយើងត្រូវអនុវត្តមានៈ

- ដំណើរការនៃការផ្តល់ត្រឡប់ទៅវិញ នូវជីជាតិដី នៅចំការដំណាំចំណីសត្វ

- ដំណើរការនៃការគ្រប់គ្រងសំអាតស្មៅចង្រៃនៅក្នុងចំការដំណាំចំណីសត្វ បន្ទាប់ពីដាំ

- ដំណើការនៃការស្រោចស្រព ដំណាំចំណីសត្វបន្ទាប់ពីដាំ ប្រសិនបើភ្លៀងមិនគ្រប់គ្រាន់

- ដំណើរការនៃការកាត់ដំណាំចំណីសត្វសមស្របតាម បច្ចេកទេស និងតាមប្រភេទដំណាំចំណីសត្វ

៦.១- ការផ្តល់ត្រឡប់មកវិញនូវជីជាតិដី នៅចំកាដំណាំចំណីសត្វ

ជាទូទៅដីដាំដុះដំណាំចំណីសត្វសម្រាប់កាត់ ដឹកជញ្ជូន ផ្តល់ទៅអោយសត្វនៅកន្លែងចិញ្ចឹម តែងតែជួបប្រទះ នូវការបាត់បង់ ឬ ចុះថយនូវជីជាតិពីក្នុងដី ជាពិសេសចំការស្មៅសម្រាប់ជាចំណីគោ ក្របី ។ សារធាតុខនិជដែលតែង តែមានការបាត់បង់ធ្ងន់ធ្ងរជាងគេនោះមាន អាសូត ផូស្វ័រ និង ប៉ូតាស្យូម ( NPK ) ដូចនេះ បើយើងពុំមានការ បំពេញបន្ថែមត្រឡប់ទៅចំការវិញទេ នោះផលប៉ះពាល់វា នឹងកើតមានឡើងដល់ដំណាំចំណីសត្វរបស់យើង នៅក្នុង ឆ្នាំទី៣ទៅឆ្នាំបន្តបន្ទាប់នៅក្នុងអំឡុងពេលដាំដុះ ។

សញ្ញាសំខាន់ៗដែលបង្ហាញអោយឃើញ ដោយការបាត់បង់នូវជីជាតិដី នៅលើស្មៅចំណីសត្វ មានដូចជាៈ

- កំរិតដុះលូតលាស់របស់ដំណាំចំណីសត្វក្រោយពេលកាត់យឺត បើប្រៀបធៀបនិងឆ្នាំដំបូង

- ដើមស្មៅធំ រឹង ចន្លោះថ្នាំងខ្លី ស្លឹកតូចខុសធម្មតា កំពស់ដើមទាមជាងឆ្នាំដំបូង

- ស្លឹកបង្ហាញនូវការប្រែពណ៌ពីបៃតង មក លឿង ហើយរឹងនិងបង្ហាញច្បាស់នូវរជ្ជូវប្រាំង

- សភាពដីនៅកន្លែងដាំហាប់ណែន ហើយប្រែពណ៌ស្រលែតខុសពីធម្មតា

លក្ខណៈទាំងអស់វានឹងកាន់តែកើតមានខ្លាំងឡើងៗ ប្រសិនបើយើងពុំមានការបង្គ្រប់ត្រឡប់ទៅវិញនូវការបាត់បង់ជីជាតិដី ។

ជាបទពិសោធន៍របស់កសិករ ដែលបានអនុវត្តរួចមកហើយឃើញថា ការដាក់បញ្ចូលវិញនូវជីលាកសត្វ ប្រមាណ ៣៥០គក្រ ក្នុង ១០០០ម២ ក្នុង១ឆ្នាំ ចាប់តាំងពីឆ្នាំដំបូងមកភាពល្អរបស់ដំណាំចំណីសត្វនឹងមានជារៀង រាល់ឆ្នាំ ។

ចំពោះប្រភេទដីដែលបាត់បង់ជីជាតិខ្លាំងគេអាចប្រើ នូវបរិមាណជីគីមីខ្ពស់បំផុតទៅលើចំការដំណាំចំណីសត្វ តាមលក្ខណៈបច្ចេកទេសដូចក្នុងតារាងខាងក្រោម ( ប្រព័ន្ធដាំស្មៅសម្រាប់ច្រូតឱ្យសត្វស៊ី)

**តារាង** កំណត់កំរិតនៃការប្រើប្រាស់ជី នៅលើចំការដំណាំចំណីសត្វ

| បរិមាណជីជាតិដីដែលបាត់បង់/ឆ្នាំ/ ១០០០ម ២ | បរិមាណជីគីមីដែលត្រូវបំពេញ/ឆ្នាំ |
|---|---|
| ៣២គក្រ/ឆ្នាំ អាសូត ( N ) | ៧០គក្រ/ឆ្នាំ អ៊ុយរ៉េ ( Urea ) |
| ២គក្រ/ឆ្នាំ ផូស្វ័រ ( P ) | ១០គក្រ/ឆ្នាំ ទ្រីផូស្វាត ( TSP ) |
| ២១គក្រ/ឆ្នាំ ប៉ូតាស្យូម K ) | ៤២គក្រ/ឆ្នាំ ប៉ូតាស្យូមក្លរ ( Kcl ) |

(Werner W.Stür and Peter M.Horne ) ។

### ៦.២- ការគ្រប់គ្រងសំអាតស្មៅចង្រៃ

ជាធម្មតាស្មៅចង្រៃដុះលូតលាស់ចាប់តាំងពីពេលដែលមានភ្លៀងធ្លាក់ដំបូង ដូចនេះវាត្រូវបានឆ្លងកាត់ការសំអាតពីរលើករួចមកហើយបន្ទាប់ពីដំណាក់កាលរៀបចំដីដាំដំណាំចំណីសត្វ។ ទោះជាយ៉ាងនេះក្តី នៅក្រោយពេលដាំវាផ្តើមដុះជាបន្តទៀត ហើយវាមានសន្ទុះលឿនជាងដំណាំចំណីសត្វនៅក្នុងអំឡុងពេល១០-១៥ថ្ងៃដំបូង។

ការកំចាត់ស្មៅចង្រៃក្រោយពេលដាំធ្វើឡើង ១-២ដង វាអាស្រ័យទៅនឹងកំរិតរាលដាលរបស់វា ជាធម្មតា គេចាប់ផ្តើមដកស្មៅចង្រៃចេញពីជួរដំណាំចំណីសត្វនៅថ្ងៃទី១៥ បន្ទាប់ពីការដាំ និងអាចធ្វើលើកទី២ប្រសិនបើកំរិត នៃការបំផ្លាញខ្លាំងក្នុងអំឡុងពេល១០-១៥ថ្ងៃ បន្ទាប់ពីធ្វើលើកទី១ លើសពីនេះដំណាំចំណីសត្វវាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដុះគ្របពីលើស្មៅចង្រៃ។

### ៦.៣- ការស្រោចស្រពដំណាំចំណីសត្វ

ជាទូទៅដំណាំចំណីសត្វយើងចាប់ផ្តើមដាំនៅដើមរដូវវស្សា ការធ្វើបែបនេះ យើងចង់ប្រើប្រាស់ទឹកភ្លៀង ដើម្បីស្រោចស្រព ។ ដំណាំចំណីសត្វភាគច្រើនវាអាចធនទ្រាំ និងរដូវប្រាំងរយៈពេលពី៥-៦ខែ ដូចនេះវាសមស្របទៅនិងអាកាសធាតុនៅក្នុងប្រទេសកម្ពុជាយើង។

**តំរូវការទឹកសម្រាប់ដំណាំចំណីប្រភេទខ្លះ**

| ល.រ | ប្រភេទដំណាំចំណីសត្វ | តំរូវការកំពស់ទឹក (mm) | ភាពធន់ទ្រាំរដូវប្រាំង(ខែ) |
|---|---|---|---|
| ១ | ហ្គាមបា ( Gamba ) | ៨០០-១៥០០ | ៥-៦ |
| ២ | បាស៊ីលីស ( Basilis ) | ៩០០-១៨០០ | ៥-៦ |
| ៣ | ម៉ារ៉ាន់ឌូ ( Marandu ) | ៩០០-១៨០០ | ៥-៦ |
| ៤ | ម៉ុលឡាតូ ( Mulato ) | ៩០០-១៨០០ | ៥-៦ |
| ៥ | ប៉ាស្ពាលូម ( Paspalum ) | ៨០០-២០០០ | ៤-៥ |
| ៦ | ក្រុមស្មៅនេពារ ( Napier grass ) | ១០០០-១៨០០ | ៥-៦ |
| ៧ | ស្មៅហ្គីនេ ( Guinea grass ) | ១១០០-១៣០០ | ៥-៦ |
| ៨ | ស្តាយឡូ ( Stylo ) | ៧០០-១០០០ | ៤-៥ |
| ៩ | ឌីសមិនធស ( Desmanthus ) | ២៥០-២០០០ | ៤-៥ |
| ១០ | គ្លីរីស៊ីដ្យា ( Gliricidia ) | ១០០០-៣៥០០ | រយៈពេលយូរ |
| ១១ | កន្ទិថេត ( Leucaena ) | ៩០០-៣៥០០ | រយៈពេលយូរ |

ការអនុវត្តដាំជាក់ស្តែងនៅតំបន់អាកាសធាតុធម្មតាក្នុងប្រទេសកម្ពុជាយើង ជាពិសេសនៅរដូវប្រាំង បើ យើងអនុវត្តត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសក្នុងការកាត់ និងថែទាំត្រឹមត្រូវ នៅតំបន់ដែលពុំមានប្រភពទឹកស្រោច ស្រព នោះគេអាចប្រមូលផលពីស្មៅចំណីសត្វបាន ១ដង ក្នុង១ខែ ទិន្នផលស្ថិតក្នុងកំរិតទាប។

នៅតំបន់ដែលមានទឹកស្រោចស្រព ៣០-៤០% នៅរដូវប្រាំង គេអាចស្រោចស្រពចំការស្មៅ១-២ដង/ខែ នោះការប្រមូលផល២ដង/ខែ ទិន្នផលទទួលបានក្នុងកំរិតមធ្យម ។

នៅតំបន់ដែលមានទឹកស្រោចស្រព១០០%ក្នុងរដូវប្រាំងមានន័យថាទឹកគ្រប់គ្រាន់តាមតំរូវការ ដូចបានរាយក្នុងតារាង ខាងលើ នោះការផ្តល់ផលស្ថិតក្នុងកំរិតអតិបរមា។

ដោយឡែកចំពោះពពួកទ្រីឡេហ្គីមមិនសូវមានបញ្ហាលើការស្រោចស្រពនៅរដូវប្រាំងឡើយ ព្រោះវាអាចដុះលូតលាស់ និងផ្តល់ផលបាន ពី ៦០-៧០%បើប្រៀបធៀបនឹងរដូវវស្សា។

### ៦.៤- កំពស់កាត់ និង ចន្លោះពេលនៃការកាត់ដំណាំចំណីសត្វ

បច្ចេកទេសក្នុងការកាត់ដំណាំចំណីសត្វ វាជាចំណុចសំខាន់ បំផុតក្នុងការគ្រប់គ្រងដំណាំចំណីសត្វ ក៏ដូចជាការថែទាំអោយដំណាំចំណីសត្វមានជីវិតរស់បានត្រឹមត្រូវតាមសមត្ថភាពរបស់វា។ ហេតុនេះការកាត់ដំណាំចំណីមានការពាក់ព័ន្ធ ទៅ និងលក្ខណៈជីវសាស្ត្រ ការដុះលូតលាស់ បរិមាណ និង គុណភាពរបស់ចំណីសម្រាប់សត្វ ។

-បើយើងកាត់ដំណាំចំណីសត្វ ដែលមានអាយុតិច វាខ្ចីល្អគុណភាពចំណីខ្ពស់ តែបរិមាណចំណីទាប

-បើយើងទុកអោយដំណាំមានអាយុច្រើនពេកទើបកាត់នោះ បរិមាណចំណីខ្ពស់តែគុណភាពចំណីធ្លាក់ចុះទាប សម្រាប់ការផ្តល់អោយសត្វស៊ី មានការលូតលាស់យឺត។

-ការកាត់ដំណាំចំណីសត្វវែងឬខ្លីពេកនាំអោយការដុះលូតលាស់យឺតឬអាចខូចខាតទាំងស្រុងក៏មាន។

-ការទុកអោយដំណាំចំណីសត្វដុះលូតលាស់វែងដោយមិនកាត់នៅរដូវប្រាំង បណ្តាលអោយវាងាប់អស់ដោយស្ថានភាពផ្គត់ផ្គង់ទឹកមិនគ្រប់គ្រាន់ ដូចនេះតំរូវអោយយើងកាត់ដំណាំចំណីសត្វ នៅចុងរដូវវស្សាដោយ មិនទុក អោយវែង។

សរុបសេចក្តីទៅការកាត់ដំណាំចំណីសត្វជាបច្ចេកទេសចាំបាច់មួយដែលយើងគួរតែមានការយល់ដឹងឬផ្សព្វផ្សាយដល់កសិករ ដែលដាំដំណាំចំណីសត្វ អោយមានការយល់ដឹងនិងអនុវត្តទទួលបានជោគជ័យ។

*ក-តារាងគំរូក្នុងការប្រមូលផលដោយការកាត់ដំណាំចំណីសត្វ*

| ល-រ | ឈ្មោះដំណាំ ចំណីសត្វ | អាយុប្រមូលផល ដំបូង ( ថ្ងៃ ) | កំពស់កាត់ធៀប នឹងផ្ទៃដី(ស.ម) | អាយុកាត់បន្ទាប់ពី កាត់លើទីមួយ (ថ្ងៃ) | ការប្រមូលផល ក្នុង១រដូវវស្សា (លើក) |
|---|---|---|---|---|---|
| ១ | Guinea | ៤៥-៦០ | ៧ | ៧-១០ | ១៥-២០ |
| ២ | Gamba | ៥០-៦០ | ៧ | ១០-១៥ | ១០-១៥ |
| ៣ | Marandu | ៥០-៦០ | ៧ | ១៥-២០ | ១០-១៥ |
| ៤ | Mullato | ៥០-៦០ | ៧ | ១៥-២០ | ១០-១៥ |
| ៥ | Basilisk | ៦០-៦៥ | ៧ | ២០-២៥ | ៧-១០ |
| ៦ | Napier | ៥០-៦០ | ១០ | ២៥-៣០ | ៦-៨ |
| ៧ | Stylo 184 | ៥០-៦០ | ១៥ | ២៥-៣០ | ៦-៨ |
| ៨ | Leucaena | ៣៥០ | ១០០-១៥០ | ២០-២៥ | ៦-៨ |
| ៩ | Gliricidia | ៣៥០ | ១០០-១៥០ | ២០-២៥ | ៦-៨ |



របៀបកាត់ស្មៅ



របៀបកាត់ពួកលេហ្គីម

## ៧. លទ្ធផលទទួលបានពីការដាំដំណាំចំណីសត្វ

តាមរយៈការដាំដំណាំចំណីសត្វនៅតាមប្លង់ដីភូមិបាន ជួយដោះស្រាយផលលំបាករបស់កសិករ ក្នុងការស្វែងរកចំណីសត្វ ជាពិសេសតំបន់ ដែលខ្វះវាលស្មៅធម្មជាតិ ។ កន្លងមកកសិករដែលបានអនុវត្តការដាំដំណាំចំណី សត្វបានទទួលនូវផលចំណេញមួយចំនួនដូចជា:

-ពួកគាត់មានដំណាំចំណីសត្វជិតផ្ទះដោយមិនចាំបាច់ចេញទៅរក ចំណីសត្វនៅទីឆ្ងាយ

-ជួយអោយកសិករកាត់បន្ថយបាន នូវការចំណាយប្រាក់សោហុយដឹកជញ្ជូនចំណីសត្វ នៅតំបន់ឆ្ងាយៗ ពី ២០០០រៀល -៤០០០រៀល ក្នុង១ថ្ងៃ សម្រាប់កំលាំងពលកម្ម និង ចំណាយលើប្រេងសាំងចាក់ម៉ូតូសម្រាប់ដឹកចំណីសត្វ ។

-កាត់បន្ថយពេលវេលាក្នុងការយក គោ ក្របី ទៅឃ្វាលដែល ពីមុនប្រើពេល ៥-៦ម៉ោង មកនៅត្រឹម ២-៣ ម៉ោង ដោយមានដំណាំ ចំណីសត្វ ជាចំណីសម្រាប់ផ្គត់ផ្គង់បន្ថែមនៅផ្ទះ ។

-ជួយអោយកសិករមានពេលវេលាក្នុងការចេញទៅប្រកបមុខរបរផ្សេងដូចជា ដកស្ទូង ដាំដំណាំផ្សេងៗ ឬលក់ដូរតូចតាច យកកំរៃលើកកំពស់ជីវភាពគ្រួសារ។

-ជួយអោយកុមារមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរៀនទៀងទាត់ពេលវេលា និងមិនបោះបង់ការរៀនសូត្រ

-ជួយអោយកសិករមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួម ការងារសង្គមដូចជា ពិធីបុណ្យប្រពៃណី

បុណ្យជាតិ និងមានឱកាសទំនាក់ទំនងរាល់គ្រប់កិច្ចការបានល្អជាងមុន។

-តាមរយៈដំណាំចំណីសត្វបានជួយអោយសត្វទទួលបាន នូវអាហារូបត្ថម្ភគ្រប់គ្រាន់ប្រកបដោយគុណភាពធំធាត់លឿនធ្វើឱ្យតម្លៃសត្វ មានការកើនឡើ រួមចំណែក បង្កើនប្រាក់ចំណូលប្រចាំគ្រួសារ។

-ផ្តល់ជាមធ្យោបាយដល់កសិករក្នុងការពង្រីកផលិតកម្មសត្វ ពិសេសបំប៉នសត្វ សម្រាប់លក់យកប្រាក់កំរៃក៏ដូចជាជួយអោយកសិករមានមុខរបរគួបផ្សំ។

-ម្យ៉ាងទៀតវាបានបំពេញនូវការខ្វះខាតចំណី ពិសេសគោ ក្របី នូវរដូវប្រាំង ដែលជាទូទៅសត្វបាត់បង់ នូវអាហារូបត្ថម្ភធ្ងន់ធ្ងរ ។

## ៨. ប្រភពគាំទ្រសកម្មភាព អនុវត្តដាំដុះដំណាំចំណីសត្វ

ក្នុងដំណើរការ ការងារដាំដំណាំចំណីសត្វ ជាលក្ខណៈគ្រួសារជាមួយកសិករ ដែលបានអនុវត្ត និង ទទួលបានជោគជ័យ អាស្រ័យទៅដោយផែនការសកម្មភាព សំខាន់ៗ មួយចំនួនដូចជា:

-ការងារ បណ្តុះបណ្តាលបុគ្គលិក អោយមានការយល់ដឹងអំពីដំណាំចំណីសត្វ

-ការងារ ជ្រើសរើសតំបន់ដាំដុះ និង កសិករសហការណ៍អោយបានសមស្រប

-ដំណើរការដាំដុះ និង ផ្តល់បច្ចេកទេសដល់កសិករ តាមរយៈ ការរៀនជាមួយ និង ការអនុវត្តផ្ទាល់

-ការងារត្រួតពិនិត្យ និង ណែនាំបច្ចេកទេសបន្ថែមដល់កសិករក្រោយពេលដាំដំណាំចំណីសត្វ

-ការងារផ្សព្វផ្សាយ និងពង្រីក សកម្មភាពដាំដុះដំណាំចំណីសត្វ

ទាំងអស់នេះវាជាផ្នែកធំៗក្នុងដំណើរការសកម្មភាព ដូចនេះសកម្មភាពអាចដំណើរការទៅបានអាស្រ័យទៅ និងការរៀបចំសំភារៈ និងអ្នកផ្គត់ផ្គង់ រួមជាមួយសំភារៈ ដែលមានស្រាប់របស់កសិករ។

ការងារមួយចំនួន ដូចជា ការបណ្តុះបណ្តាល បុគ្គលិក សកម្មភាពជ្រើសរើសទីតាំងចំណាយលើការផ្តល់សេវា និងពូជដំណាំចំណីសត្វ សម្រាប់ការងារដាំដុះលើកដំបូង សេវាបុគ្គលិកការងារ ទាំងនេះវាជាសកម្មភាពបានមកពីការ ជួយឧបត្ថម្ភ ពីគំរោង ឬ អង្គការដៃគូរអភិវឌ្ឍន៍ សហការជាមួយក្រសួង ឬនាយកដ្ឋានសាម៉ី។

សំភារៈសម្រាប់បំរើអោយការងារដាំដុះ កំលាំពលកម្មផ្ទៃដីដាំដុះ និងសំភារៈការពារសុវត្ថិភាពដំណាំចំណីសត្វរួមជាមួយនិងជីសម្រាប់បំរើអោយ ការកែលំអរគុណភាពដី ទាំងនេះវាជាភារៈ របស់កសិករដែលជាអ្នកសហការណ៍។

សរុបសេចក្តីទៅយើងឃើញថា កសិករកម្ពុជានាពេលបច្ចុប្បន្នកំពុងជួបប្រទះផលលំបាក លើផ្នែកកង្វះខាត ចំណីសម្រាប់ផ្តល់អោយសត្វ ជាពិសេសចំណីសម្រាប់គោ ក្របី តំរូវអោយយើងទាំងអស់គ្នា សហការណ៍ដោះស្រាយ។

តែទោះជាយ៉ាងណាក៏ដោយ ការងារនេះ ត្រូវជួបប្រទះនូវភាពស្មុគស្មាញខ្លះ នៅក្នុងដំណើរការដំបូង នៃសកម្មភាពកែលំអរ ព្រោះថា វាជាជំហ៊ានចាប់ផ្តើម ការយល់ដឹងរបស់កសិករ ទៅលើបច្ចេកទេសនេះនៅមានកំរិត។

តាមរយៈការងារដែលបានអនុវត្តកន្លងមក និងភាពទទួលយកយ៉ាងឆាប់រហ័ស និងតំរូវការពិតប្រាកដរបស់កសិករនោះយើងមានជំនឿជឿជាក់ថាការងារផ្សព្វផ្សាយការដាំដុះដំណាំចំណីសត្វ ពិតជាជោគជ័យថ្មីមួយសម្រាប់ជា ការរួមវិភាគទានលើកស្ទួយសេដ្ឋកិច្ចជាតិនៅពេលខាងមុខ។

ជាបញ្ចប់យើងខ្ញុំទាំងអស់គ្នា រង់ចាំទទួលនូវការកែលំអរគ្រប់បែបយ៉ាងពី សំណាក់ លោក លោស្រី ដែលមានបំណង ចូលរួមស្ថាបនាឯកសានេះ និង សូមអរគុណទុកជាមុនប្រកបដោយសេចក្តីសង្ឃឹម។

## ៩. ថវិកាសម្រាប់ការធ្វើបង្ហាញ

ថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយ នឹងប្រែប្រួលអាស្រ័យលើតម្រូវការជាក់ស្តែងនៃសាមីអង្គភាព។ តារាង ថវិកាខាងក្រោមបានបង្កើតឡើងក្នុងឆ្នាំ២០០៦ ដោយយោងទៅលើការប៉ាន់ស្មានលើបទដ្ឋានអនុវត្តបច្ចេកវិទ្យា របស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

| **ថវិកា និង ការសន្មត់** | ចំនួន/តម្លៃ |
|---|---|
| ក្រុមកសិករ (ក) | ៣០ នាក់ |
| ទុនសម្រាប់ទីកន្លែងធ្វើបង្ហាញ (ខ) | $១៨០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (គ)<br>- ឯកសារ/ការណែនាំពីបច្ចេកវិទ្យា TIP | $៣០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (ឃ)<br>- អាហារសំរ៉ន់ | $៩០ |
| ទុនចូលរួមពីកសិករគំរូ (ង) | **កំលាំងពលកម្ម / សួនស្មៅ / សំភារៈសម្រាប់ដាំ** |
| ទិវាស្រែ - អាហារសំរ៉ន់ (ច) | $២៥ |
| ទិវាស្រែ - សំភារៈ (ឆ) | $១០ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ជ)<br>- ការបណ្តុះបណ្តាល, ការត្រួតពិនិត្យទីកន្លែងធ្វើបង្ហាញ | $៤២ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ (ឈ) | $២៤ |
| ការចុះត្រួតពិនិត្យ-តាមដាននៅមូលដ្ឋានដោយអ្នកឯកទេស (ញ) | $២០ |
| **សរុប** | **$៤២១** |

### ការសន្មត់ប្រើប្រាស់មាន

ក. ក្នុង TIP មួយ មានក្រុមកសិករ (៣០នាក់) និងទីកន្លែងបង្ហាញ ២កន្លែង

ខ. ទុនសម្រាប់ធ្វើបង្ហាញអំពីដំណាំចំណីសត្វតំបន់វាលទំនាប ដោយមានបញ្ចូលទាំង គ្រាប់ពូជ/ដើមសម្រាប់កាត់ដាំ= $២៥ ធ្វើរបង= $៣០ កំលាំងអូសទាញ =4១៥ ការផ្គត់ផ្គង់ទឹក = $១០ ជីកំប៉ុស្តិ៍/គីមី= $១០ សរុបរួម= $៩០ ទុនសម្រាប់ពីរកន្លែង =4៩០ x ២= $១៨០។

គ. ឯកសារបណ្តុះបណ្តាលបច្ចេកវិទ្យា មានរួមបញ្ចូលទាំងសំភារៈសម្រាប់បង្រៀន មេរៀន ការបញ្ចាំងស្លាយ និង ផ្ទាំងរូបភាពធំៗ ដែលជាដំណើរការនៃវិធីសាស្ត្របង្រៀន ។

ឃ. ការបណ្តុះបណ្តាលក្រុមកសិករមាន ៣វគ្គ មួយវគ្គ មានរយៈពេលមួយថ្ងៃ លើកលែងតែវគ្គ ការធ្វើជីកំប៉ុស្តិ៍ មានតែ ២វគ្គទេ និង ការកំណត់ចំណាត់ថ្នាក់ដី មានមួយវគ្គ

ង. ទុនចូលរួមរបស់កសិករ ដី ៤០០ម២ ឧបករណ៍ ទឹកសម្រាប់ស្រោចស្រពនិងកំលាំងពលកម្ម

ច. ទិវាស្រែមានកន្លះថ្ងៃមានតែម្តងក្នុងវគ្គណាមួយក្នុងចំណោមវគ្គទាំងបី និងអាចមានការចូលរួមពីកសិករនៅក្បែរៗ ភូមិប្រហែល ៤០ ទៅ ៦០នាក់។

ឆ. សំភារៈសម្រាប់ទិវាស្រែរួមមាន ឧឃោសនស័ព្ទ (មេក្រូ) ផ្ទាំងក្រដាស់ប្លាស្ទិក និងផ្ទាំងបដារូបភាពផ្សេងៗទៀត

ជ. សម្រាប់មន្ត្រីកសិកម្មស្រុក ថវិកាឧបត្ថម្ភរួមមាន ៤ថ្ងៃ សម្រាប់ការជ្រើសរើសទីកន្លែងបង្ហាញ ឬ ការចាប់ផ្តើម ឬ ការត្រួតពិនិត្យតាមដាន។ ចំពោះការបណ្តុះបណ្តាលសម្រាប់ ៣វគ្គ ផ្តល់អោយ ៦ថ្ងៃ និងទិវាស្រែផ្តល់អោយ ២ថ្ងៃ។

ឈ. ប្រាក់ឧបត្ថម្ភសម្រាប់ម៉ូតូ ២ដុល្លាសម្រាប់មួយថ្ងៃ ទាំងអស់ ១២ថ្ងៃ

៣. មន្ទីរកសិកម្មខេត្ត-អ្នកឯកទេសជំនាញផ្តល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យ-តាមដានការបណ្តុះបណ្តាល TIP

# ឯកសារយោង

1- Peter M. Horne and W. Stur   Developing forage technologies  with smallholder farmers
Published by ACIAR and CIAT
2- L.'t Mannetje and R.M. Jones 1992 Plant Resources of South-East Asia 4  Forages
3- Alan Robertson  February-March 1998
FORAGE PRODUCTION SYSTEM IN CAMBODIA